**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងខេត្តស្វាយរៀង

-សំណុំរឿងព្រហ្មទណ្ឌ
លេខ ២៩
ចុះថ្ងៃទី ៣០-០១-២០២២
-សំណុំរឿងជំនុំជម្រះ
លេខ ១៨៣
ចុះថ្ងៃទី ២៣-០៨-២០២២
-សាលក្រមព្រហ្មទណ្ឌ
លេខ ២៧៧ "ឃ"
ចុះថ្ងៃទី ២៣-១១-២០២២

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តស្វាយរៀង

បានបើកសវនាការជាសាធារណៈ នៅសាលសវនាការ នៃសាលាដំបូងខេត្តស្វាយរៀង នាថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២២ វេលាម៉ោង ០៨ និង ០០ នាទីព្រឹក ដោយមានសមាសភាពជំនុំជម្រះដូចតទៅ៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

-លោក [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
-លោក [redacted] ចៅក្រមប្រឹក្សា
-លោកស្រី [redacted] ចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

-លោក [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តស្វាយរៀង

**ក្រឡាបញ្ជីសវនាការ**

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តស្វាយរៀង

**ដើម្បីជំនុំជម្រះ**

លើសំណុំរឿងព្រហ្មទណ្ឌលេខ ២៩ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០២២ ដែលមាន៖

១-ជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ២៨ឆ្នាំ កើតឆ្នាំ១៩៩៣ ជនជាតិខ្មែរ មុខរបរជាងផ្សារដែក ទីកន្លែងកំណើតនៅភូ[redacted]ខេត្តកណ្តាល ទីលំនៅបច្ចុប្បន្ននៅភូមិធំ ឃុំធ្លក ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ឪពុកឈ្មោះ [redacted]លី (ស្លាប់) ម្តាយឈ្មោះ [redacted] **សុខឃីម** (រស់) ប្រពន្ធឈ្មោះ [redacted] គ្មានកូន ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន ជានីតិជន ។ (ក្នុងឃុំ)

-ឃាត់ខ្លួនថ្ងៃទី២៨-០១-២០២២ ឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៩៧ ប.ឃខ/២២ ចុះថ្ងៃទី៣០-០១-២០២២

-មានលោកមេធាវី[redacted] មានអាសយដ្ឋានការិយាល័យមេធាវីភូមិកៀនសាំង សង្កាត់ស្វាយរៀង ក្រុងស្វាយរៀង ខេត្តស្វាយរៀង ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] លីស៊ីផន ។

ជាប់ចោទពីបទ **ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅក្នុងក្រុងស្វាយរៀង ខេត្តស្វាយរៀង កាលពីអំឡុងឆ្នាំ២០១២ រហូតដល់ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៣ និងទី៥ និងមាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។



Scanned with CamScanner

២-ជនជាប់ចោទឈ្មោះ [redacted]រតនា ហៅ ប្រជៀវ ភេទប្រុស អាយុ២៤ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើតនៅភូមិ[redacted] ខេត្តស្វាយរៀង ទីលំនៅបច្ចុប្បន្ននៅភូ[redacted] ខេត្តស្វាយរៀង ឪពុកឈ្មោះ [redacted]អូន (ស្លាប់) ម្តាយឈ្មោះ [redacted] សុន (រស់) ប្រពន្ធឈ្មោះ សន ចរិយា មានកូន០១នាក់ ធ្លាប់ជាប់ពន្ធនាគារ០២ឆ្នាំ ពាក់ព័ន្ធបទល្មើសគ្រឿងញៀន ជានីតិជន ។ (ក្នុងឃុំ)

-ឃាត់ខ្លួនថ្ងៃទី២៧-០១-២០២២ ឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៩១ ប.ឃខ/២២ ចុះថ្ងៃទី៣០-០១-២០២២

៣-ជនជាប់ចោទឈ្មោះ [redacted] ឡុង ភេទប្រុស អាយុ៣២ឆ្នាំ ជនជាតិខ្មែរ មុខរបរបើករ៉ឺម៉កដឹកទឹកសុទ្ធ ទីកន្លែងកំណើតនៅភូ[redacted]ខេត្តកំពត ទីលំនៅបច្ចុប្បន្ននៅភូមិជៀសឫស្សី ឃុំកំពង់ចំឡង ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ឪពុកឈ្មោះ[redacted] ធី (រស់) ម្តាយឈ្មោះ[redacted]មុំ (រស់) ប្រពន្ធឈ្មោះ[redacted]វណ្ណី មានកូន០១នាក់ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន ជានីតិជន ។ (ក្នុងឃុំ)

-ឃាត់ខ្លួនថ្ងៃទី២៧-០១-២០២២ ឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៩៣ ប.ឃខ/២២ ចុះថ្ងៃទី៣០-០១-២០២២

៤-ជនជាប់ចោទឈ្មោ[redacted]សីហា ហៅ ប្រុស ភេទប្រុស អាយុ៣២ឆ្នាំ កើតឆ្នាំ១៩៨៨ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើតនៅ[redacted] ខេត្តស្វាយរៀង ទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ខេត្តស្វាយរៀង ឪពុកឈ្មោះ[redacted]សុវណ្ណ (ស្លាប់) ម្តាយឈ្មោះ [redacted] សាម៉ន (រស់) ប្រពន្ធឈ្មោះ [redacted]សុជាតិ មានកូន០២នាក់ ធ្លាប់ជាប់ពន្ធនាគារ៨ខែ ជានីតិជន ។ (ក្នុងឃុំ)

-ឃាត់ខ្លួនថ្ងៃទី២៧-០១-២០២២ ឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៩៥ ប.ឃខ/២២ ចុះថ្ងៃទី៣០-០១-២០២២

៥-ជនជាប់ចោទឈ្មោះ[redacted] ចន្ថា ភេទប្រុស អាយុ២៩ឆ្នាំ កើតឆ្នាំ១៩៩៣ ជនជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើតនៅភូ[redacted] ខេត្តស្វាយរៀង ទីលំនៅបច្ចុប្បន្ននៅ[redacted]ខេត្តស្វាយរៀង ឪពុកឈ្មោះ[redacted]ផាត (រស់) ម្តាយឈ្មោះ[redacted] រ៉ា (រស់) ប្រពន្ធឈ្មោះ [redacted] ចិនស្តា មានកូន០២នាក់ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន ជានីតិជន ។ (ក្នុងឃុំ)

-ឃាត់ខ្លួនថ្ងៃទី២៧-០១-២០២២ ឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ១០៣ ប.ឃខ/២២ ចុះថ្ងៃទី៣០-០១-២០២២

៦-ជនជាប់ចោទឈ្មោះ[redacted] ដារ៉ា ហៅ ឈុយ ភេទប្រុស អាយុ២៤ឆ្នាំ កើតឆ្នាំ១៩៩៨ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើតនៅភូ[redacted] ខេត្តស្វាយរៀង ទីលំនៅបច្ចុប្បន្ននៅ [redacted] ខេត្តស្វាយរៀង ឪពុកឈ្មោះ [redacted] ស៊ីណា (រស់) ម្តាយឈ្មោះ [redacted] បុប្ផា (រស់) នៅលីវ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន ជានីតិជន ។ (ក្នុងឃុំ)

-ឃាត់ខ្លួនថ្ងៃទី២៧-០១-២០២២ ឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ១០១ ប.ឃខ/២២ ចុះថ្ងៃទី៣០-០១-២០២២

-មានលោកមេធាវី [redacted] ជាសមាជិកមេធាវីនៃក្រុមហ៊ុនមេធាវី ជីជី អន្តរជាតិ ដែលស្ថិតនៅអាគារលេខ ២២៤D ផ្លូវលេខ២០ ភូមិព្រែកតាឡុង១ សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ និងលោកមេធាវី[redacted] ជាសមាជិកមេធាវីនៃក្រុមហ៊ុនមេធាវី ក្រុមមេធាវី ខេមររដ្ឋ ដែលមានការិយាល័យស្ថិតនៅផ្ទះលេខ ២៤$E_0E_1$ ផ្លូវលេខ៤៩ សង្កាត់ផ្សារថ្មីទី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ ទិត្យ ដារ៉ា ។

៧-ជនជាប់ចោទឈ្មោះ[redacted] ចាន់ឌីណា ភេទប្រុស អាយុ២២ឆ្នាំ កើតឆ្នាំ២០០០ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើតនៅភូមិធ្លក ឃុំធ្លក ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ទីលំនៅបច្ចុប្បន្ននៅភូមិធ្លក ឃុំធ្លក ស្រុក

ស្វាយជ្រំ ខេត្តស្វាយរៀង ឪពុកឈ្មោះ [redacted] សាម៉េន (រស់) ម្ដាយឈ្មោះ [redacted] និន (រស់) នៅលីវ ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការ គ្មាន ជាទីតិជន ។ (ក្នុងឃុំ)

-ឃាត់ខ្លួនថ្ងៃទី២៨-០១-២០២២ ឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៩៩ ប.ឃខ/២២ ចុះថ្ងៃទី៣០-០១-២០២២

ជាប់ចោទពីបទ **ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅក្នុងក្រុងស្វាយរៀង ខេត្តស្វាយរៀង កាលពីអំឡុងឆ្នាំ២០១២ រហូតដល់ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៣ និងទី៤ និងមាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

៨-ជនជាប់ចោទឈ្មោះ [redacted] **សុចិន្តា** ភេទប្រុស អាយុ២៣ឆ្នាំ កើតឆ្នាំ១៩៩៩ ជនជាតិខ្មែរ មុខរបរជាងភ្លើងម៉ាស៊ីនត្រជាក់ ទីកន្លែងកំណើតនៅ [redacted] ខេត្តស្វាយរៀង ទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ខេត្តស្វាយរៀង ឪពុកឈ្មោះ [redacted] ដក (រស់) ម្ដាយឈ្មោះ [redacted] សុផុន (រស់) ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការ គ្មាន ជាទីតិជន ។ (ក្នុងឃុំ)

-ឃាត់ខ្លួនថ្ងៃទី២៧-០១-២០២២ ឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ១០៧ ប.ឃខ/២២ ចុះថ្ងៃទី៣០-០១-២០២២

ជាប់ចោទពីបទ **ចាត់ចែងឲ្យប្រើប្រាស់ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅក្នុងក្រុងស្វាយរៀង ខេត្តស្វាយរៀង កាលពីអំឡុងឆ្នាំ២០១២ រហូតដល់ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤២ កថាខណ្ឌទី១ និងទី២ និងមាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

៩-ជនជាប់ចោទឈ្មោះ [redacted] **ធារិទ្ធ** ភេទប្រុស អាយុ២៥ឆ្នាំ ជនជាតិខ្មែរ មុខរបរកម្មកររោងចក្រ ទីកន្លែងកំណើតនៅ [redacted] ខេត្តស្វាយរៀង ទីលំនៅបច្ចុប្បន្ននៅភូមិស្វាយរៀង សង្កាត់ស្វាយរៀង ក្រុងស្វាយរៀង ខេត្តស្វាយរៀង ឪពុកឈ្មោះ [redacted] ណារិន (រស់) ម្ដាយឈ្មោះ [redacted] ម៉ាលីស (រស់) នៅលីវ ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការ គ្មាន ជាទីតិជន ។ (ក្រៅឃុំ)

ជាប់ចោទពីបទ **ចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅក្នុងក្រុងស្វាយរៀង ខេត្តស្វាយរៀង កាលពីអំឡុងឆ្នាំ២០១២ រហូតដល់ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤២ កថាខណ្ឌទី១ និងទី២ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

១០-ជនជាប់ចោទឈ្មោះ [redacted] **ម៉ាឡែន** ភេទប្រុស អាយុ៣២ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើតនៅភូ [redacted] ខេត្តស្វាយរៀង ទីលំនៅបច្ចុប្បន្ននៅភូមិស្វាយរៀង សង្កាត់ស្វាយរៀង ក្រុងស្វាយរៀង ខេត្តស្វាយរៀង ឪពុកឈ្មោះ [redacted] សុផល (រស់) ម្ដាយឈ្មោះ [redacted] រ៉ (រស់) ប្រពន្ធឈ្មោះ [redacted] ប៊ុនសុជាតា មានកូន០២នាក់ ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការ គ្មាន ជាទីតិជន ។ (ក្រៅឃុំ)

ជាប់ចោទពីបទ **ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅក្នុងក្រុងស្វាយរៀង ខេត្តស្វាយរៀង កាលពីអំឡុងឆ្នាំ២០១២ រហូតដល់ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

-បានឃើញ របាយការណ៍សំយោគលេខ ០០៥ រ.ប.ក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២២ របស់ការិយាល័យប្រឆាំងគ្រឿងញៀន នៃស្នងការដ្ឋាននគរបាលខេត្តស្វាយរៀង ។

-**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ **១៩ អ.យ.គ** ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងខេត្តស្វាយរៀង ។

-**បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ ១៥៨ អ.យ.ឃ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងខេត្តស្វាយរៀង ។

-**បានឃើញ** ដីកាដំណោះស្រាយលេខ ១១៧០ (ច) ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តស្វាយរៀង ។

-**បានឃើញ** ដីកាសម្រេចចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះលេខ **១៩៣ ជ.ស.រ/២២** ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២២ របស់ប្រធានសាលាដំបូងខេត្តស្វាយរៀង ។

-**បានឃើញ** ដីកាបង្គាប់ឲ្យនាំជនជាប់ចោទមកតុលាការលេខ **១០៤៩១/២២** ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងខេត្តស្វាយរៀង ។

## អង្គហេតុដែលកើតមានឡើង

កាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០២២ វេលាម៉ោង១១និង៤០នាទី ប្រជាពលរដ្ឋបានរាយការណ៍តាមរយៈទូរស័ព្ទប្រាប់សមត្ថកិច្ចថា នៅចំណុចភូមិមេភ្លើង សង្កាត់ស្វាយរៀង ក្រុងស្វាយរៀង ខេត្តស្វាយរៀង មានមុខសញ្ញាសង្ស័យកំពុងធ្វើសកម្មភាពជួញដូរ និងប្រើប្រាស់គ្រឿងញៀន ។ ក្រោយពីទទួលបានព័ត៌មានកម្លាំងការិយាល័យប្រឆាំងគ្រឿងញៀនខេត្ត សហការជាមួយកម្លាំងអធិការដ្ឋាននគរបាលក្រុងស្វាយរៀង ចុះស្រាវជ្រាវដល់កន្លែងកើតហេតុ ឈានទៅបង្ក្រាប និងឃាត់ខ្លួនបានជនសង្ស័យជាបន្តបន្ទាប់បានចំនួន០៧នាក់ មានឈ្មោះ [redacted] រតនា ហៅ ប្រជៀវ ភេទប្រុស អាយុ៣២ឆ្នាំ ឈ្មោះ [redacted] ដារ៉ា ហៅ ឈុយ ភេទប្រុស អាយុ២៤ឆ្នាំ ឈ្មោះ [redacted] ចន្ថា ភេទប្រុស អាយុ២៩ឆ្នាំ ឈ្មោះ [redacted] ម៉ាឡែន ភេទប្រុស អាយុ៣២ឆ្នាំ ឈ្មោះ [redacted] សុចិន្តា ភេទប្រុស អាយុ២៣ឆ្នាំ ឈ្មោះ [redacted] ឡុង ភេទប្រុស អាយុ៣២ឆ្នាំ និងឈ្មោះ [redacted] សីហា ភេទប្រុស អាយុ៣៤ឆ្នាំ ធ្វើការឆែកឆេរលើដងខ្លួននៅកន្លែងកើតហេតុ រកឃើញ និងដកហូតសម្ភារៈវត្ថុតាងសរុបមានម្សៅក្រាមពណ៌សថ្លាសង្ស័យចំនួន០៥កញ្ចប់ ទូរស័ព្ទដៃចំនួន០៧គ្រឿង និងម៉ូតូចំនួន០២គ្រឿង រួចនាំមកការិយាល័យប្រឆាំងគ្រឿងញៀន ដើម្បីសាកសួរបំភ្លឺ និងធ្វើតេស្តទឹកម៉ូត្រស្វែងរកសារធាតុញៀន លទ្ធផលវិជ្ជមាន ជាប្រភេទមេតំហ្វេតាមីន ។ តាមចម្លើយសារភាពរបស់ឈ្មោះ [redacted] រតនា ហៅ ប្រជៀវ បានបញ្ជាក់ថា ខ្លួនធ្លាប់ចូលលុយគ្នាទិញថ្នាំញៀនយកមកប្រើប្រាស់ជាមួយឈ្មោះ [redacted] ធារិទ្ធ ភេទប្រុស ដោយឈ្មោះនេះជាអ្នកទៅទិញថ្នាំញៀន ។ ក្រោយមកក៏បានស្គាល់ឈ្មោះ [redacted] ហៅ កាតឿ ភេទស្រី អាយុប្រហែល២៣ឆ្នាំ ស្រីខារ៉ាអូខេខ្យល់ត្រជាក់ ដោយបានណែនាំខ្លួនឲ្យស្គាល់ឈ្មោះ ឌីណា ភេទប្រុស អាយុប្រហែល២៦ឆ្នាំ ដែលជាអ្នកលក់ថ្នាំញៀន រួចខ្លួនក៏ទាក់ទងទិញថ្នាំញៀនពីឈ្មោះ ឌីណា នេះ ដើម្បីលក់ចែកចាយបន្ត និងប្រើប្រាស់ជាមួយឈ្មោះ ក្លា និងឈ្មោះ អាដា និងទិញពីឈ្មោះ [redacted] សីហា ។ តាមចម្លើយសារភាពរបស់ឈ្មោះ [redacted] ចន្ថា បានបញ្ជាក់ថា ខ្លួនធ្លាប់ស្គាល់ឈ្មោះ ជា ភេទប្រុស អាយុប្រហែល៣០ឆ្នាំ រស់នៅរាជធានីភ្នំពេញ ជាអ្នកបបួលខ្លួនប្រើប្រាស់គ្រឿងញៀន ដោយចូលលុយគ្នា ហើយឈ្មោះ ជា ជាអ្នកទៅទិញថ្នាំញៀនយកមកប្រើប្រាស់ ។ បន្ទាប់មកទៀតក៏បានទិញថ្នាំញៀនពីឈ្មោះ [redacted] ដារ៉ា យកមករំលែកលក់និងចែកចាយបន្ត ។ តាមចម្លើយសារភាពរបស់ឈ្មោះ [redacted] សីហា បានបញ្ជាក់ថា ខ្លួនធ្លាប់ទិញថ្នាំញៀនពីឈ្មោះ មុំ ភេទប្រុស អាយុប្រហែល២១ឆ្នាំ រស់នៅរាជធានីភ្នំពេញ ដើម្បីយកមកប្រើប្រាស់ជាមួយឈ្មោះ [redacted] រតនា និងឈ្មោះ [redacted] ម៉ាឡែន ។ តាមចម្លើយសារភាពរបស់ឈ្មោះ កង ម៉ាឡែន បានបញ្ជាក់ថា ខ្លួនធ្លាប់ចូលលុយគ្នាជាមួយឈ្មោះ ចយ និងឈ្មោះ ប្រុស ហើយឈ្មោះ ចយ និងឈ្មោះ

ប្រុស ជាអ្នកទៅទិញថ្នាំញៀន ពេលបានថ្នាំញៀនយកមកប្រើប្រាស់នៅផ្ទះរបស់ឈ្មោះ ប្រុស តែម្តង ។ តាមចម្លើយសារភាពរបស់ឈ្មោះ [redacted] ដារ៉ា បានបញ្ជាក់ថា កន្លងមកឈ្មោះ ណាង ភេទប្រុស អាយុប្រហែល២០ឆ្នាំ បានបបួលខ្លួនប្រើប្រាស់ថ្នាំញៀននៅក្នុងបន្ទប់ជួលតែម្តង ។ បន្ទាប់មកក៏បានស្គាល់ឈ្មោះ ចាន់ថា ភេទប្រុស អាយុប្រហែល៣៥ឆ្នាំ រស់នៅឃុំបាសាក់ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង រួចក៏បានទាក់ទងទិញថ្នាំញៀនយកមករំលែកលក់ និងចែកចាយបន្តខ្លះ ទុកប្រើប្រាស់ខ្លួនឯងខ្លះ ។ តាមចម្លើយសារភាពរបស់ឈ្មោះ [redacted] សុចិន្តា បានបញ្ជាក់ថា ខ្លួនធ្លាប់ចូលលុយគ្នាជាមួយឈ្មោះ ម៉ាប់ ភេទប្រុស អាយុប្រហែល២៤ឆ្នាំ ដើម្បីទិញថ្នាំញៀនមកប្រើប្រាស់ ហើយឈ្មោះ ម៉ាប់ ជាអ្នកទៅទិញថ្នាំញៀន ។ តាមចម្លើយសារភាពរបស់ឈ្មោះ [redacted] ឡុង បានបញ្ជាក់ថា ខ្លួនចេះប្រើប្រាស់ថ្នាំញៀនតាមរយៈឈ្មោះ ភិន ភេទប្រុស អាយុប្រហែល៤៤ឆ្នាំ រស់នៅខេត្តប៉ៃលិន ជាអ្នកយកថ្នាំញៀនមកឲ្យខ្លួនប្រើប្រាស់ ។ តាមចម្លើយសារភាពរបស់ឈ្មោះ លាង ចាន់ឌីណា បានបញ្ជាក់ថា ខ្លួនចេះប្រើប្រាស់ថ្នាំញៀនតាមរយៈឈ្មោះ វ័ត្ត ភេទប្រុស អាយុប្រហែល២០ឆ្នាំ រស់នៅភូមិឃុំជាមួយគ្នា ឈ្មោះ គ ភេទប្រុស អាយុប្រហែល៣៤ឆ្នាំ រស់នៅភូមិអំពៅព្រៃ ឃុំផ្កុក ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ឈ្មោះ គង់ ភេទប្រុស អាយុប្រហែល២២ឆ្នាំ រស់នៅឃុំម៉ឺនជ័យ ស្រុករំដួល ខេត្តស្វាយរៀង ឈ្មោះ ទិត ភេទប្រុស អាយុប្រហែល២៧ឆ្នាំ រស់នៅភូមិកណ្តាល ឃុំផ្កុក ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង និងឈ្មោះ ពៅ ភេទប្រុស អាយុប្រហែល២៤ឆ្នាំ រស់នៅភូមិកណ្តាល ឃុំផ្កុក ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង បានបបួលខ្លួនប្រើប្រាស់ថ្នាំញៀន ដោយចូលលុយគ្នាទិញ ហើយឈ្មោះ គ ជាអ្នកទៅទិញថ្នាំញៀន ។ ក្រោយមកក៏មានគេទាក់ទងមកខ្លួនទិញថ្នាំញៀន ខ្លួនក៏ទាក់ទងទៅឈ្មោះ គ ដើម្បីទិញថ្នាំញៀនបន្ត ។ តាមចម្លើយសារភាពរបស់ឈ្មោះ ហុង លីស៊ីថន បានបញ្ជាក់ថា ខ្លួនចេះប្រើប្រាស់ថ្នាំញៀនតាមរយៈបុរសមិនស្គាល់ឈ្មោះដែលកាន់លេខទូរស័ព្ទ ០៩៧៣៣៤៣៣១២ ដែលជាមេក្លោងជួញដូរគ្រឿងញៀន រស់នៅផ្សារកអណ្តើក ហើយគាត់ក៏ធ្លាប់ឲ្យខ្លួនយកថ្នាំញៀនទៅឲ្យគេបានចំនួន០៦ដង ។ បន្ទាប់មកសមត្ថកិច្ច ក៏បន្តស្រាវជ្រាវរហូតដល់ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២២ វេលាម៉ោង ១៣ និង ៣០ នាទី ឈានទៅឃាត់ខ្លួនបាន ជនសង្ស័យឈ្មោះ លាង ចាន់ឌីណា ភេទប្រុស អាយុ២១ឆ្នាំ និងឈ្មោះ ហុង លីស៊ីថន ភេទប្រុស អាយុ២៨ឆ្នាំ បន្ថែមទៀត ធ្វើការឆែកឆេរលើឯងខ្លួននៅកន្លែងកើតហេតុរកឃើញ និងដកហូតសម្ភារៈវត្ថុតាងមាន ថ្នាំញៀនចំនួន១១កញ្ចប់ ទូរស័ព្ទដៃចំនួន០២គ្រឿង និងម៉ូតូចំនួន០៤គ្រឿង រួចនាំមកការិយាល័យប្រឆាំងគ្រឿងញៀនខេត្ត ដើម្បីសាកសួរបំភ្លឺ និងធ្វើតេស្តទឹកម៉ូត្រស្វែងរកសារធាតុញៀន លទ្ធផលវិជ្ជមានជាមេតំហ្វេតាមីន ។ ក្រោយពីសាកសួររួច សមត្ថកិច្ចក៏បានកសាងសំណុំរឿងបញ្ជូនមកអយ្យការចាត់ការតាមនីតិវិធី ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] លីស៊ីថន បានឆ្លើយថា ខ្ញុំបានឆ្លើយសារភាពទទួលស្គាល់ការចោទប្រកាន់ ។ ដំបូងសមត្ថកិច្ចឃាត់ខ្លួន បានដកហូតទូរស័ព្ទ ម៉ូតូ និងចិញ្ចៀន នាឡិកា កាបូបលុយ ។ ម៉ូតូបានយកទៅវិញរួចហើយ ហើយបានដកហូតថ្នាំញៀន២កញ្ចប់ ដោយគេផ្ញើមកពីផ្សារកអណ្តើក យកទៅឲ្យគេនៅស្វាយតាយាន ដោយឈ្មោះ ប៉ក់ ហើយគេបានឲ្យឈ្នួល១៥ម៉ឺនរៀល ថ្លៃយកឲ្យគេ តែពុំទាន់បានយកឲ្យគេនោះទេ ។ កន្លងមក ខ្ញុំធ្លាប់យកឲ្យគេបាន៦ដងហើយ ហើយកន្លងមក ខ្ញុំធ្លាប់ប្រើប្រាស់គ្រឿងញៀន។ ប្រាក់១៥ម៉ឺនរៀលនោះ ថ្លៃយកគ្រឿងញៀនឲ្យគេ ។ ខ្ញុំពុំធ្លាប់លក់គ្រឿងញៀនឲ្យគេនោះទេ ធ្លាប់តែបានយកគ្រឿងញៀនឲ្យគេ ហើយគេឲ្យថ្លៃយកទៅឲ្យគេ ។ ខ្ញុំទទួលស្គាល់ថា ពិតជាបានប្រើប្រាស់គ្រឿងញៀនប្រាកដមែន។ ខ្ញុំបានយកថ្នាំញៀនឲ្យគេ ហើយបានថ្លៃឈ្នួល១៥ម៉ឺនរៀល ។ ខ្ញុំបានដឹងកំហុសហើយ ហើយសន្យាថា កែខ្លួនឈប់ប្រព្រឹត្តហើយ ។



Scanned with CamScanner

-ជនជាប់ចោទឈ្មោះ [redacted] ដារ៉ា បានឆ្លើយថា សមត្ថកិច្ចបានឃាត់ខ្លួនខ្ញុំនៅម្តុំស្ទួនតាខី ករណីប្រើប្រាស់ និងជួញដូរគ្រឿងញៀន ហើយពេលឃាត់ខ្លួនមានតែម្នាក់ឯងនោះទេ ។ ពេលគេឃាត់ខ្លួនមានថ្នាំញៀន១កញ្ចប់តូច ១៦លេខ ។ ពេលនោះ ខ្ញុំកំពុងជិះម៉ូតូ ហើយក៏មានសមត្ថកិច្ចមកឃាត់ខ្លួន តែមុនពេលឃាត់ខ្លួន ខ្ញុំបានជក់គ្រឿងញៀនរួចហើយ។ ក្នុងចំណោមជនជាប់ចោទទាំងអស់ ខ្ញុំស្គាល់តែឈ្មោះ [redacted] សុចិន្តា ម្នាក់នោះទេ ។ គ្រឿងញៀន ខ្ញុំបានទិញពីគេ យកមកប្រើប្រាស់ ដោយទិញម្តងៗ១០ដុល្លារ ទៅ១៥ដុល្លារ ។ ខ្ញុំពុំដែលយកថ្នាំញៀនទៅលក់ ឬចែកចាយឱ្យអ្នកណានោះទេ ។ ពីមុនខ្ញុំធ្លាប់ធ្វើការនៅក្រុងបាវិត ហើយក៏បានប្រើប្រាស់ជាមួយអ្នកធ្វើការ និងបានពឹងមិត្តភក្តិឱ្យជួយទិញថ្នាំញៀនយកមកប្រើប្រាស់ ហើយបានប្រើជាមួយមិត្តភក្តិតែ២នាក់នោះទេ ។ ឈ្មោះ [redacted] សុចិន្តា ខ្ញុំស្គាល់ ដោយសារធ្លាប់ធ្វើការជាមួយគ្នា ចំណែកឈ្មោះ [redacted] ចន្ថា ពុំស្គាល់នោះទេ ។ ថ្នាំញៀន ខ្ញុំទិញពីគេ តាមលេខទូរស័ព្ទ ហើយពេលទិញបានយកមកប្រើប្រាស់ម្នាក់ឯង ។ ឈ្មោះ [redacted] ខ្ញុំទើបតែស្គាល់បាន១ឆ្នាំ ។ ខ្ញុំទទួលស្គាល់ថា បានប្រើប្រាស់គ្រឿងញៀនប្រាកដមែន ។ ខ្ញុំពុំធ្លាប់បានយកថ្នាំញៀនពីឈ្មោះ [redacted] សុចិន្តា នោះទេ ហើយក៏ពុំដែលលក់គ្រឿងញៀនឱ្យឈ្មោះ [redacted] សុចិន្តា នោះដែរ ។ ខ្ញុំពុំដែលធ្លាប់បានយកគ្រឿងញៀន ទៅវ៉ែលកលក់ឱ្យអ្នកណានោះទេ ។ ខ្ញុំពុំដែលស្គាល់ឈ្មោះ [redacted] ចន្ថា នោះទេ ។

-ជនជាប់ចោទឈ្មោះ [redacted] សុចិន្តា បានឆ្លើយថា ខ្ញុំដឹងពីការចោទប្រកាន់ គឺបទជួញដូរ និងប្រើគ្រឿងញៀន ។ ខ្ញុំប្រើប្រាស់គ្រឿងញៀន ហើយសមត្ថកិច្ចក៏ឃាត់ខ្លួន ហើយឈ្មោះ [redacted] ដារ៉ា ខ្ញុំស្គាល់ ដោយធ្លាប់ធ្វើការជាមួយគ្នា ។ ចម្លើយដែលខ្ញុំបានឆ្លើយថា ឈ្មោះ [redacted] ដារ៉ា បានយកថ្នាំញៀនឱ្យខ្ញុំនោះ គឺខ្ញុំសូមរក្សាទុកដដែល ។ ពេលយកថ្នាំញៀននោះ ខ្ញុំពុំបានឱ្យលុយទៅឈ្មោះ ទិត្យ ដារ៉ា នោះទេ ហើយក៏ពុំដែលបានយកទៅលក់នោះដែរ ។ ពេលឃាត់ខ្លួន បានដកហូតបានថ្នាំញៀន១កញ្ចប់តូច ។ ហើយថ្នាំញៀននេះ គឺគេផ្ញើមកឱ្យខ្ញុំ ហើយឈ្មោះ ទិត្យ ដារ៉ា ជាអ្នកយកមកឱ្យខ្ញុំ ដោយគេផ្ញើតាមរយៈឈ្មោះ [redacted] ដារ៉ា ។ ហើយពេលខ្ញុំកំពុងជិះម៉ូតូក៏មានសមត្ថកិច្ចមកឃាត់ខ្លួននៅម្តុំ គយត្របែក ។ ខ្ញុំពុំដែលទិញគ្រឿងញៀនពីអ្នកណានោះទេ ។

-ជនជាប់ចោទឈ្មោះ [redacted]រតនា បានឆ្លើយថា ចំពោះជនជាប់ចោទទាំងអស់ ខ្ញុំស្គាល់ឈ្មោះ[redacted] សីហា ហើយពេលឃាត់ខ្លួនពុំមានដកហូតបានគ្រឿងញៀននោះទេ តែមានសារធាតុញៀននៅក្នុងខ្លួន ។ ពេលឃាត់ខ្លួន គឺខ្ញុំនៅក្នុងផ្ទះ ។ កន្លងមក ខ្ញុំធ្លាប់បានទិញថ្នាំញៀនពីឈ្មោះ សុឌីណា និងធ្លាប់បានប្រើជាមួយឈ្មោះ សីហា ចំនួន៣ដងដែរ ។ ខ្ញុំពុំមានការងារនោះទេ ខ្ញុំនៅផ្ទះ ហើយរៀនបានថ្នាក់ទី៣ ។ ខ្ញុំធ្លាប់ជាប់ពន្ធនាគារពីបទល្មើសគ្រឿងញៀន ។

-ជនជាប់ចោទឈ្មោះ[redacted]សីហា បានឆ្លើយថា ពេលគេឃាត់ខ្លួន ខ្ញុំកំពុងធ្វើមាន់ ហើយបានដកហូតគ្រឿងញៀន១កញ្ចប់ និងទូរស័ព្ទ១គ្រឿង ។ ខ្ញុំទិញថ្នាំញៀនពីភ្នំពេញ នៅម្តុំអូរឫស្សី តម្លៃ២០០០០រៀល យកមកប្រើប្រាស់ម្នាក់ឯង ។ ក្រៅពីនេះ ខ្ញុំពុំបានទិញពីអ្នកណានោះទេ ។ ខ្ញុំស្គាល់ឈ្មោះ កង ម៉ាឡែន ដោយធ្លាប់រាប់អាន និងជក់ថ្នាំញៀនជាមួយគ្នា ។ ខ្ញុំពុំធ្លាប់ទិញថ្នាំញៀនយកមកលក់ចែកចាយឱ្យអ្នកណានោះទេ ។

-ជនជាប់ចោទឈ្មោះ[redacted]ឡុង បានឆ្លើយថា ខ្ញុំពុំស្គាល់អ្នកទាំងអស់នេះទេ ស្គាល់តែឈ្មោះ ប្រចៀវ រស់នៅប្រសូត្រ តែឈ្មោះ[redacted]រតនា នេះ គឺខ្ញុំពុំស្គាល់នោះទេ ។ ពេលឃាត់ខ្លួនដកហូតបានថ្នាំញៀន១កញ្ចប់តូច រួមទាំងទូរស័ព្ទ១គ្រឿង ។ ថ្នាំញៀននេះទម្ងន់១៧លេខ ។ ចំពោះគ្រឿងញៀន ខ្ញុំទិញតែពីឈ្មោះ ប្រចៀវ នោះទេ ពេលឃាត់ខ្លួននៅផ្សារ ពេលកំពុងយកទឹកសុទ្ធដាក់ឱ្យគេ ។ ថ្នាំញៀនឆែកឃើញនៅលើខ្លួនខ្ញុំ ហើយយកទៅជក់នៅកន្លែងធ្វើការ ។

-ជនជាប់ចោទឈ្មោះ[redacted] ចន្ថា បានឆ្លើយថា ខ្ញុំត្រូវបានគេឃាត់ខ្លួន ដកហូតបានដែកកេះ និងទុយោ តែពុំមានគ្រឿងញៀននោះទេ ។ ពេលឃាត់ខ្លួននៅតាមផ្លូវ ដោយមកពីបួមទឹក ។ ខ្ញុំមកពីទិញស្រាហូប ។ រាល់ដង ខ្ញុំជក់តែម្នាក់ឯង ហើយធ្លាប់ជក់នៅភ្នំពេញ ជាមួយឈ្មោះ ជា ។ ខ្ញុំទិញពីគេនៅម្តុំក្តាន់២ ម្តង៣០ដុល្លារ ដោយផ្ញើឱ្យគេទិញឱ្យ។ ខ្ញុំពុំដែល

ទិញពីគេនៅខេត្តស្វាយរៀងនោះទេ ។ ខ្ញុំពុំធ្លាប់លក់គ្រឿងញៀននោះទេ ។ ខ្ញុំត្រូវបានគេឃាត់ខ្លួននៅម៉ោង៣រសៀល នៅតូបលក់ដូរ នៅសំយ៉ាប ។ ខ្ញុំពុំស្គាល់ឈ្មោះ ទិត្យ ដារ៉ា នោះទេ ។ ចម្លើយកន្លងមក ខ្ញុំឆ្លើយថា ស្គាល់ឈ្មោះ [redacted] ដារ៉ា នោះ ខ្ញុំសូមបដិសេធ ។

-ជនជាប់ចោទឈ្មោះ [redacted] ចាន់ឌីណា បានឆ្លើយថា គេឃាត់ខ្លួនខ្ញុំនៅក្បែរផ្ទះ ហើយមានគេទាក់ទងមកទិញថ្នាំញៀន ដោយឈ្មោះ [redacted] រតនា ជាអ្នកទាក់ទងមកទិញថ្នាំញៀនពីខ្ញុំ ។ ពេលឃាត់ខ្លួនមានទូរស័ព្ទ និងថ្នាំញៀន៩កញ្ចប់ ហើយថ្នាំញៀននេះ គឺខ្ញុំបំណងយកទៅឱ្យឈ្មោះ [redacted] រតនា តែពុំបានឱ្យទេ ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួន ។ ខ្ញុំទិញថ្នាំញៀនពីគេនៅភ្នំពេញ នៅម្តុំក្តាន់២ តែពុំស្គាល់ឈ្មោះនោះទេ ។ ខ្ញុំទិញពីគេតម្លៃ១០ម៉ឺនរៀល ។ ហើយលក់ឱ្យគេវិញ តម្លៃ១២ម៉ឺនរៀល ។ ខ្ញុំពុំធ្លាប់លក់ឱ្យអ្នកផ្សេងនោះទេ ។ ខ្ញុំធ្លាប់ប្រើគ្រឿងញៀន ហើយមានសារធាតុញៀននៅក្នុងខ្លួន ។ ថ្នាំញៀនដែលដកហូតបានពីលើខ្លួនខ្ញុំមាន៩កញ្ចប់ ប្រភេទមេតំហ្វេតាមីន។ ម៉ូតូដកហូតបានពីខ្ញុំ ហើយជារបស់ប៉ាខ្ញុំ និងបានស្នើសុំយកទៅប្រើវិញហើយ។ ខ្ញុំពុំដែលប្រើគ្រឿងញៀនជាមួយឈ្មោះ [redacted] ស៊ីលីថន ។

-ជនជាប់ចោទឈ្មោះ [redacted] ម៉ាឡែន បានឆ្លើយថា ខ្ញុំបានប្រើប្រាស់គ្រឿងញៀន ហើយពេលឃាត់ខ្លួននៅផ្ទះរបស់ឈ្មោះ [redacted] សីហា ដោយពេលនោះ ខ្ញុំបានឱ្យឈ្មោះ [redacted] សីហា ជូនទៅផ្ទះ ហើយក៏មានសមត្ថកិច្ចចុះមកឃាត់ខ្លួនឈ្មោះ [redacted] សីហា ហើយខ្ញុំនៅទីនោះដែរ ក៏គេឱ្យតេស្តទឹកនោមមានសារធាតុញៀន ។ ខ្ញុំពុំមានថ្នាំញៀននៅលើខ្លួននោះទេ ។ ខ្ញុំធ្លាប់ជក់ថ្នាំញៀនជាមួយឈ្មោះ [redacted] សីហា តែពុំដែលទិញថ្នាំញៀនពីគាត់នោះទេ ហើយក៏ពុំដែលលក់គ្រឿងញៀននោះដែរ ។

-សាក្សីឈ្មោះ [redacted] សភារ៉ា បានឆ្លើយថា ចំពោះប្រតិបត្តិការនេះ គឺខ្ញុំសូមរក្សាចម្លើយដែលបានឆ្លើយនៅចំពោះមុខចៅក្រមស៊ើបសួរ ទុកជាបានការដដែល និងសូមរក្សារបាយការណ៍របស់ការិយាល័យប្រឆាំងគ្រឿងញៀន ទុកជាបានការដដែល ។ ចំពោះពាក់ព័ន្ធនឹងអង្គហេតុ និងការកសាងសំណុំរឿងនេះ ដោយសារតាមរយៈចម្លើយរបស់ជនជាប់ចោទទាំងអស់បានឆ្លើយមកមានការទាក់ទងគ្នា សមត្ថកិច្ចក៏បានកសាងជាសំណុំរឿងតែមួយ បញ្ជូនមកតំណាងអយ្យការចាត់ការតាមនីតិវិធី ។

**-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា៖** ក្រោយពីបានស្តាប់ការពិភាក្សាដេញដោល ក្រោយពីបានពិនិត្យសំណុំរឿងចប់សព្វគ្រប់ តំណាងអយ្យការយល់ឃើញថា តាមចម្លើយសារភាពនាពេលសវនាការរបស់ជនជាប់ចោទ និងចម្លើយរបស់សាក្សីជាមន្ត្រីនគរបាលយុត្តិធម៌ អាចបញ្ជាក់បានថា ជនជាប់ចោទពិតជាបានប្រព្រឹត្តអំពើដូចការចោទប្រកាន់របស់តំណាងអយ្យការពិតប្រាកដមែន ។ ដូចនេះតំណាងអយ្យការសុំតម្កល់បទចោទ និងដីកាសន្និដ្ឋានស្ថាពររបស់តំណាងអយ្យការ ទុកជាបានការដដែល និងប្តឹងសុំក្រុមប្រឹក្សាជំនុំជម្រះពិចារណាសម្រេចផ្តន្ទាទោសទៅតាមច្បាប់ ។

-លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ដារ៉ា បានធ្វើសេចក្តីសន្និដ្ឋានការពារថា ក្រោយពីបានស្តាប់ការពិភាក្សាដេញដោល ក្រោយពីបានពិនិត្យសំណុំរឿងចប់សព្វគ្រប់ យល់ឃើញថា តាមចម្លើយរបស់កូនក្តីខ្ញុំ រួមទាំងចម្លើយរបស់ជនជាប់ចោទផ្សេងទៀត ឃើញថា កូនក្តីខ្ញុំបានឆ្លើយសារភាពថា ខ្លួនគ្រាន់តែបានប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនតែប៉ុណ្ណោះ ហើយគ្រឿងញៀនដែលកូនក្តីខ្ញុំបានទិញយកមក គឺក្នុងគោលបំណងដើម្បីយកទៅប្រើប្រាស់ផ្ទាល់ខ្លួនតែប៉ុណ្ណោះ ដោយពុំបានយកទៅលក់ចែកចាយដូចការចោទប្រកាន់របស់តំណាងអយ្យការនោះឡើយ ហើយតាមចម្លើយរបស់ជនជាប់ចោទផ្សេងទៀត ក៏មានភាពស៊ីសង្វាក់ទៅនឹងចម្លើយរបស់កូនក្តីខ្ញុំ ដែលបញ្ជាក់បានថា ពុំមានភស្តុតាងណាមួយដាក់បន្ទុកទៅលើកូនក្តីខ្ញុំថា បានជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ។ ហេតុដូច្នេះ ក្នុងនាមយើងខ្ញុំជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ដារ៉ា ស្នើសុំតុលាការឱ្យកូនក្តីខ្ញុំបានរួចផុតពីបទចោទប្រកាន់ពីបទជួញដូរដោយខុសច្បាប់នូវសារធាតុញៀនមកលើរូបកូនក្តីខ្ញុំ ។



Scanned with CamScanner

-លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] លីស៊ីថន បានធ្វើសេចក្តីសន្និដ្ឋានការពារថា ក្រោយពីបានស្តាប់ការពិភាក្សាដេញដោល ក្រោយពីបានពិនិត្យសំណុំរឿងចប់សព្វគ្រប់ យល់ឃើញថា តាមចម្លើយរបស់កូនក្តីខ្ញុំបាទ រួមទាំងចម្លើយរបស់ជនជាប់ចោទផ្សេងទៀត ឃើញថា កូនក្តីខ្ញុំបានឆ្លើយសារភាពថា ខ្លួនគ្រាន់តែបានយកគ្រឿងញៀន ទៅឱ្យគេតែប៉ុណ្ណោះ ដោយពុំបានជួញដូរដោយខុសច្បាប់នូវសារធាតុញៀននោះឡើយ ហើយកូនក្តីខ្ញុំគ្រាន់តែបានទទួលប្រាក់ឈ្នួល ផ្ញើយកគ្រឿងញៀនទៅឱ្យគេតែប៉ុណ្ណោះ ដែលឃើញថា អំពើរបស់កូនក្តីខ្ញុំនេះ គឺពុំមានលក្ខណៈធ្ងន់ធ្ងរនោះឡើយ ហើយម្យ៉ាងវិញទៀត កូនក្តីខ្ញុំក៏បានឆ្លើយសារភាពទទួលស្គាល់កំហុសរួចហើយដែរ ដែលបង្ហាញថា កូនក្តីខ្ញុំមានការភ្ញាក់រលឹក ដឹងកំហុស ដូចនេះ ខ្ញុំស្នើសុំតុលាការមេត្តាបន្ធូរបន្ថយទោសឱ្យកូនក្តីខ្ញុំដោយបានទាបបំផុត ។

-ជនជាប់ចោទឈ្មោះ [redacted] ចន្ថា ឈ្មោះ [redacted] ឡុង ឈ្មោះ [redacted] សីហា ឈ្មោះ [redacted] រតនា ឈ្មោះ [redacted] លីស៊ីថន ឈ្មោះ [redacted] សុចិន្តា ឈ្មោះ [redacted] ចាន់ឌីណា និងឈ្មោះ [redacted] ម៉ាឡែន បាននិយាយសំដីចុងក្រោយថា សំណូមពរដល់តុលាការឱ្យជួយបន្ធូរបន្ថយទោស ។

-ជនជាប់ចោទឈ្មោះ [redacted] ដារ៉ា បាននិយាយសំដីចុងក្រោយថា សំណូមពរដល់តុលាការបន្ធូរបន្ថយទោស និងលើកលែងទោសពីបទជួញដូរគ្រឿងញៀន ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ ។

-ក្រោយពីបានស្តាប់ចម្លើយរបស់សាក្សី ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ។

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ ។

-ក្រោយពីបានពិនិត្យឯកសារភស្តុតាងត្រឹមត្រូវហើយ ។

-ក្រោយពីបានពិនិត្យ ពិចារណា និងពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ ។

## <u>សំអាងហេតុ</u>

-**យល់ឃើញថា** តាមមាត្រា ៤០ កថាខណ្ឌទី៣ ទី៤ និងទី៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន បានចែងថា៖ “ការផ្តល់សម្រាប់លក់ ការលក់ ការទិញដើម្បីលក់ ឬដោះដូរ ការដោះដូរដោយខុសច្បាប់នូវសារធាតុញៀន គឺជាអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ។ បទរក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀនដែលស្ថិតនៅក្នុងតារាងទី ១ និងតារាងទី ២ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២(ពីរ)ឆ្នាំ ទៅ ៥(ប្រាំ)ឆ្នាំ ។ ក្រៅពីទោសដាក់ពន្ធនាគារ ជនល្មើសនឹងអាចត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ៤.០០០.០០០(បួនលាន)រៀល ទៅ ១០.០០០.០០០(ដប់លាន)រៀល ។ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥(ប្រាំ)ឆ្នាំ ទៅ ១០(ដប់)ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ពី ១០.០០០.០០០(ដប់លាន)រៀល ទៅ ២០.០០០.០០០(ម្ភៃលាន)រៀល ក្នុងករណីដែលការប្រព្រឹត្តបទល្មើស ស្ថិតក្នុងស្ថានភាពណាមួយដូចខាងក្រោមនេះ : ៦-អំហ្វេតាមីន មេតំហ្វេតាមីន ឬអ៊ិចស្តាស៊ី មានបរិមាណសុទ្ធចាប់ពី ១៥(ដប់ប្រាំ)ក្រាម រហូតដល់ក្រោម ៨០(ប៉ែតសិប)ក្រាម ។” តាមមាត្រា ៤២ កថាខណ្ឌទី១ និងទី២ នៃច្បាប់ដដែល បានចែងថា៖ “អំពើជួយដល់អ្នកដទៃឱ្យប្រើប្រាស់គ្រឿងញៀនតាមគ្រប់រូបភាព អំពើដឹកនាំ បែងចែក បញ្ចា ឬចែកចាយ ដើម្បីបញ្ចូលសារធាតុញៀនទៅក្នុងរាងកាយអ្នកដទៃ គឺជាអំពើចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ។ បទចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដែលស្ថិតនៅក្នុងតារាងទី ១ និងតារាងទី ២ តាមគ្រប់មធ្យោបាយ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២(ពីរ)ឆ្នាំ ទៅ ៥(ប្រាំ)ឆ្នាំ ។ ក្រៅពីទោសដាក់ពន្ធនាគារជនល្មើស អាចត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី

៤.០០០.០០០(បួនលាន)រៀល ទៅ ១០.០០០.០០០(ដប់លាន)រៀល ។" និងតាមមាត្រា **៤៥** កថាខណ្ឌទី១ នៃច្បាប់ដដែលនេះ បានចែងថា៖ "ជនណាប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនដែលស្ថិតនៅក្នុងតារាងទី ១ និងតារាងទី ២ តាមគ្រប់រូបភាព និងធ្លាប់ត្រូវបានទទួលរងនូវវិធានការព្យាបាលដោយបង្ខំ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ)ខែ ទៅ ៦(ប្រាំមួយ)ខែ និងអាចត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០០.០០០(មួយសែន)រៀល ទៅ ១.០០០.០០០(មួយលាន)រៀល ។" ។

**-យល់ឃើញពីហេតុការណ៍នៃអំពើល្មើស៖** កាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០២២ វេលាម៉ោង១១និង៤០នាទី សមត្ថកិច្ចបានចុះបង្ក្រាបបទល្មើសគ្រឿងញៀន នៅចំណុចភូមិមេភ្លើង សង្កាត់ស្វាយរៀង ក្រុងស្វាយរៀង ខេត្តស្វាយរៀង និងឃាត់ខ្លួនបានជនជាប់ចោទចំនួន០៧នាក់ មានឈ្មោះ [redacted]រតនា ហៅ ប្រជៀវ ឈ្មោះ [redacted] ដារ៉ា ហៅ ឈុយ ឈ្មោះ [redacted] ចន្ថា ឈ្មោះ [redacted] ម៉ាឡែន ឈ្មោះ [redacted] សុចិន្តា ឈ្មោះ [redacted]ឡុង និងឈ្មោះ[redacted]សីហា ធ្វើការឆែកឆេរលើដងខ្លួននៅកន្លែងកើតហេតុ រកឃើញ និងដកហូតសម្ភារៈវត្ថុតាងសរុបមានម្សៅក្រាមពណ៌សថ្លាចំនួន០៥កញ្ចប់ ទូរស័ព្ទដៃចំនួន០៧គ្រឿង និងម៉ូតូចំនួន០២គ្រឿង រួចនាំទៅការិយាល័យប្រឆាំងគ្រឿងញៀន ដើម្បីសាកសួរបំភ្លឺ និងធ្វើតេស្តទឹកម៉ូត្រស្វែងរកសារធាតុញៀន លទ្ធផលវិជ្ជមាន ជាប្រភេទមេតំហ្វេតាមីន ។ តាមចម្លើយរបស់ជនជាប់ចោទដែលបានឃាត់ខ្លួនខាងលើនៅមានជនដែលជាប់ពាក់ព័ន្ធមួយចំនួនទៀត បន្ទាប់មកសមត្ថកិច្ចក៏បន្តស្រាវជ្រាវបន្តរហូតដល់ថ្ងៃទី២៨ ខែមករា ឆ្នាំ ២០២២ វេលាម៉ោង ១៣ និង ៣០ នាទី ឈានទៅឃាត់ខ្លួនបាន ជនជាប់ចោទឈ្មោះ លាង ចាន់ឌីណា និងឈ្មោះ [redacted]លីស៊ីថន ភេទប្រុស អាយុ២៨ឆ្នាំ បន្ថែមទៀត ធ្វើការឆែកឆេរលើដងខ្លួននៅកន្លែងកើតហេតុរកឃើញ និងដកហូតសម្ភារៈវត្ថុតាងមាន ថ្នាំញៀនចំនួន១១កញ្ចប់ ទូរស័ព្ទដៃចំនួន០២គ្រឿង និងម៉ូតូចំនួន០៤គ្រឿង រួចនាំទៅការិយាល័យប្រឆាំងគ្រឿងញៀនខេត្ត ដើម្បីសាកសួរបំភ្លឺ និងធ្វើតេស្តទឹកម៉ូត្រស្វែងរកសារធាតុញៀន លទ្ធផលវិជ្ជមាន ជាមេតំហ្វេតាមីន ។ តាមចម្លើយសារភាពរបស់ឈ្មោះ [redacted]រតនា ហៅ ប្រជៀវ បានបញ្ជាក់ថា ខ្លួនធ្លាប់ចូលលុយគ្នាទិញថ្នាំញៀនយកមកប្រើប្រាស់ជាមួយឈ្មោះ[redacted] ធារិទ្ធ ដោយឈ្មោះនេះជាអ្នកទៅទិញថ្នាំញៀន ។ ក្រោយពីសាកសួររួច សមត្ថកិច្ចក៏បានកសាងសំណុំរឿងបញ្ជូនមកតុលាការចាត់ការតាមនីតិវិធី ។

-តាមរបាយការណ៍សំយោគលេខ ០០៥ រ.ប.ក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២២ របស់ការិយាល័យប្រឆាំងគ្រឿងញៀន នៃស្នងការដ្ឋាននគរបាលខេត្តស្វាយរៀង បានសន្និដ្ឋានថា ជនជាប់ចោទឈ្មោះ [redacted] រតនា ឈ្មោះ [redacted]សីហា ឈ្មោះ [redacted] ចាន់ឌីណា ឈ្មោះ [redacted] លីស៊ីថន ឈ្មោះ[redacted] ដារ៉ា ឈ្មោះ [redacted] ឡុង ឈ្មោះ [redacted] សុចិន្តា ឈ្មោះ [redacted] ម៉ាឡែន និងឈ្មោះ [redacted] ចន្ថា ពិតជាបានប្រព្រឹត្តបទល្មើស ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន កាលពីអំឡុងឆ្នាំ២០១២ រហូតដល់ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២២ ក្នុងក្រុងស្វាយរៀង ខេត្តស្វាយរៀង ប្រាកដមែន ។

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted]លីស៊ីថន បានឆ្លើយនៅដំណាក់កាលសមត្ថកិច្ច ចៅក្រមស៊ើបសួរ និងនាពេលសវនាការ ដែលមានន័យប្រហាក់ប្រហែលគ្នាថា៖ កាលពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០២២ ប្រហែលម៉ោង ១៤ រសៀល ខ្លួនកំពុងលេងបុកប៊ីយ៉ែ ស្រាប់តែមានសមត្ថកិច្ចមកធ្វើការឃាត់ខ្លួន និងដកហូតបានទូរស័ព្ទម៉ាក OPPO ពណ៌ប្រផេះ ចំនួន០១គ្រឿង នាឡិកាចំនួន០១គ្រឿង ចិញ្ចៀនចំនួន០១វង់ និងលុយចំនួន១៥ម៉ឺនរៀល រួចនាំទៅផ្ទះរបស់ខ្លួនហើយធ្វើការឆែកឆេរបានរកឃើញថ្នាំញៀននៅលើកញ្ចែងស្លាបកង្ហាចំនួន០២កញ្ចប់ ។ ដោយឈ្មោះ ប៉ក់ ភេទប្រុស អាយុប្រហែល៣០ឆ្នាំ រស់នៅផ្សារកអណ្តើក បានពឹងឱ្យខ្លួនយកថ្នាំញៀន ទៅលក់ឱ្យជនមិនស្គាល់ឈ្មោះ ហើយឈ្មោះ ប៉ក់ បានឱ្យថ្លៃឈ្នួលក្នុងមួយលើក២០ម៉ឺនរៀល ដោយឈ្មោះ ប៉ក់ បានពឹងពាក់ខ្លួនឱ្យយកថ្នាំញៀនទៅឱ្យជនមិនស្គាល់ឈ្មោះបានចំនួន០៦ដង ។ ចំពោះថ្នាំញៀនដែលខ្លួនយក ទៅឱ្យជនមិនស្គាល់ឈ្មោះនោះ គឺបានមកពីឈ្មោះ ប៉ក់។ កន្លងមកខ្លួនក៏



Scanned with CamScanner

ធ្លាប់ប្រើប្រាស់ថ្នាំញៀនជាមួយឈ្មោះ ប៉ក់ បានចំនួន០៦ដង ដោយប្រើប្រាស់លើកចុងក្រោយនៅថ្ងៃទី០៥ ខែមករា ឆ្នាំ២០២២ ។ ខ្លួនក៏ធ្លាប់បានលក់ថ្នាំញៀនទៅឱ្យឈ្មោះ [redacted] ចាន់ឌីណា បានចំនួន០៣ដង លក់ម្តងៗតម្លៃ០២ម៉ឺនរៀល ។ ចំពោះថ្នាំញៀនចំនួន០៩កញ្ចប់ ចុងក្រោយដែលសមត្ថកិច្ចចាប់បាន ហើយឈ្មោះ ណាង ចាន់ឌីណា ថាទិញពីខ្លួន ខ្លួនមិនបានដឹងទេ ។

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ដារ៉ា បានឆ្លើយនៅដំណាក់កាលសមត្ថកិច្ចថា៖ ខ្លួនចេះប្រើប្រាស់គ្រឿងញៀន អំឡុងឆ្នាំ២០១៩ ពេលខ្លួនទៅធ្វើការនៅកាស៊ីណូក្រុងបាវិត ហើយបានស្គាល់ឈ្មោះ ណាង បានបបួលខ្លួនប្រើប្រាស់ថ្នាំញៀននៅក្នុងបន្ទប់ជួលរបស់គេតែម្តង ។ ខ្លួនបានចូលលុយគ្នាជាមួយឈ្មោះ ណាង ម្នាក់ចំនួន២ម៉ឺនរៀល ឈ្មោះ ណាង ជាអ្នកទៅទិញ តែខ្លួនពុំដឹងថាគេទៅទិញពីអ្នកណា នៅកន្លែងណានោះទេ ហើយពេលប្រើប្រាស់រួចក៏បែកគ្នាទៅដេករៀងៗខ្លួន ។ ក្រោយមកខ្លួនបានឈប់សម្រាកពីការងារវិលត្រឡប់មកផ្ទះវិញ រហូតដល់ចុងឆ្នាំ២០២០ ខ្លួនមានទំនាក់ទំនងស្គាល់ឈ្មោះ ចាន់ថា ដែលជាអ្នកលក់ចែកចាយថ្នាំញៀន ហើយខ្លួនបានទិញថ្នាំញៀនពីឈ្មោះ ចាន់ថា បានចំនួន០៤ដង ម្តងក្នុងតម្លៃ១០ម៉ឺនរៀល យកមករំលែកលក់ចែកចាយបន្ត និងទុកប្រើប្រាស់ខ្លួនឯងខ្លះ ។ រហូតដល់ថ្ងៃទី២៧ ខែមករា ឆ្នាំ២០២២ វេលាម៉ោងប្រហែល ១២និង៣០នាទី មានគេទូរស័ព្ទមករកទិញថ្នាំញៀនចំនួន១០ម៉ឺនរៀល រហូតដល់ម៉ោងប្រហែល១៤ និង១០នាទី ពេលខ្លួនទៅដល់កន្លែងណាត់ជួបក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួន រួមនិងវត្ថុតាងតែម្តង ។

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ដារ៉ា បានឆ្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរ និងនាពេលសវនាការ ដែលមានន័យប្រហាក់ប្រហែលគ្នាថា៖ សមត្ថកិច្ចបានឃាត់ខ្លួននៅម្តុំស្ទូនតាឌី ករណីប្រើប្រាស់ និងជួញដូរគ្រឿងញៀន ហើយពេលឃាត់ខ្លួនមានតែម្នាក់ឯងនោះទេ ។ ពេលគេឃាត់ខ្លួនមានថ្នាំញៀន១កញ្ចប់តូច១៦លេខ ។ ពេលនោះខ្លួនកំពុងជិះម៉ូតូ ហើយក៏មានសមត្ថកិច្ចមកឃាត់ខ្លួន តែមុនពេលឃាត់ខ្លួន ខ្លួនបានជក់គ្រឿងញៀនរួចហើយ ។ ក្នុងចំណោមជនជាប់ចោទទាំងអស់ ខ្លួនស្គាល់តែឈ្មោះ [redacted] សុចិន្តា ម្នាក់នោះទេ ។ គ្រឿងញៀន ខ្លួនបានទិញពីគេ យកមកប្រើប្រាស់ ដោយទិញម្តងៗ១០ដុល្លារ ទៅ១៥ដុល្លារ ។ ខ្លួនពុំដែលយកថ្នាំញៀនទៅលក់ ឬចែកចាយឱ្យអ្នកណានោះទេ ។ ពីមុនខ្លួនធ្លាប់ធ្វើការនៅក្រុងបាវិត ហើយក៏បានប្រើប្រាស់ជាមួយអ្នកធ្វើការ និងបានពឹងមិត្តភក្តិឱ្យជួយទិញថ្នាំញៀនយកមកប្រើប្រាស់ ហើយបានប្រើជាមួយមិត្តភក្តិតែ២នាក់នោះទេ ។ ឈ្មោះ [redacted] សុចិន្តា ខ្លួនស្គាល់ ដោយសារធ្លាប់ធ្វើការជាមួយគ្នា ចំណែកឈ្មោះ [redacted] ចន្ថា ពុំស្គាល់នោះទេ ។ ថ្នាំញៀនខ្លួនទិញពីគេ តាមលេខទូរស័ព្ទ ហើយពេលទិញបានយកមកប្រើប្រាស់ម្នាក់ឯង ។ ឈ្មោះ ចិន្តា ខ្លួនទើបតែស្គាល់បាន១ឆ្នាំ ។ ខ្លួនទទួលស្គាល់ថា បានប្រើប្រាស់គ្រឿងញៀនប្រាកដមែន ។ ខ្លួនពុំធ្លាប់បានយកថ្នាំញៀនពីឈ្មោះ [redacted] សុចិន្តា នោះទេ ហើយក៏ពុំដែលលក់គ្រឿងញៀនឱ្យឈ្មោះ [redacted] សុចិន្តា នោះដែរ ។ ខ្លួនពុំដែលធ្លាប់បានយកគ្រឿងញៀន ទៅរំលែកលក់ឱ្យអ្នកណានោះទេ ។ ខ្លួនពុំដែលស្គាល់ឈ្មោះ [redacted] ចន្ថា នោះទេ ។

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សុចិន្តា បានឆ្លើយនៅដំណាក់កាលសមត្ថកិច្ច ចៅក្រមស៊ើបសួរ និងនាពេលសវនាការ ដែលមានន័យប្រហាក់ប្រហែលគ្នាថា៖ កាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០២២ ប្រហែលម៉ោង ៣រសៀល ខ្លួនបានជិះម៉ូតូពីគយត្របែក ដើម្បីទៅយកថ្នាំនៅរង្វង់មូលនាគព័ន្ធពីឈ្មោះ [redacted] ដារ៉ា ហៅ ឈុយ ចំនួន០១កញ្ចប់ យកមកជក់ម្នាក់ឯង ទិញតម្លៃ២ម៉ឺនរៀលក្នុងមួយកញ្ចប់ ។ ខ្លួនបានផ្ញើទិញថ្នាំញៀនពីឈ្មោះ [redacted] ដារ៉ា ចំនួន០៣ដង ដោយទិញម្តងចំនួន០១កញ្ចប់ ក្នុងតម្លៃ២ម៉ឺនរៀល ហើយផ្ញើទិញលើកចុងក្រោយនៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០២២ ។ ក្រោយពីទទួលថ្នាំញៀនពីឈ្មោះ [redacted] ដារ៉ា ខ្លួនបានជិះម៉ូតូទៅមើលគេលេងបាល់នៅទីរួ បន្ទាប់មកក៏ត្រូវសមត្ថកិច្ចធ្វើការឃាត់ខ្លួន និងបានដកហូតថ្នាំញៀន ចំនួន០១កញ្ចប់ ទម្ងន់០.៣២ក្រាម ម៉ូតូវីវ៉ាចំនួន០១គ្រឿង ពណ៌ខ្មៅ មិនចាំស្លាកលេខ និងកាបូបដាក់ឧបករណ៍ ធ្វើភ្លើងចំនួន០១ ។ កន្លងមកខ្លួនក៏បានចូលលុយគ្នាទិញថ្នាំញៀនជាមួយឈ្មោះ ម៉ាប់ រស់នៅក្រុងប៉ោយប៉ែត ចំនួន០២ទៅ០៣ដង យកមកជក់ជាមួយគ្នាក្នុងបន្ទប់ជួលនៅក្រុងប៉ោយប៉ែត ។ ថ្នាំញៀនដែលខ្លួនប្រើប្រាស់

កន្លងមក បានទិញពីជនដែលមិនស្គាល់ឈ្មោះ តាមទូរស័ព្ទ ហើយថ្នាំញៀនជននោះបានផ្ញើតាមឈ្មោះ ទិត្យ ដារ៉ា មកឱ្យខ្លួន ហើយខ្លួនបានផ្ញើលុយតាមឈ្មោះ [redacted] ដារ៉ា ទៅឱ្យជននោះវិញ ដោយមិនបានជួបគ្នាផ្ទាល់ទេ ។ ខ្លួនទិញថ្នាំញៀនពីជននោះបានចំនួន០៣ដង ម្តងៗតម្លៃ២ម៉ឺនរៀល ។ ថ្នាំញៀនដែលខ្លួនទិញ គឺយកមកប្រើប្រាស់តែម្នាក់ឯង មិនបានយកទៅលក់ ឬចែកចាយបន្តឱ្យនរណានោះទេ ។

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] រតនា បានឆ្លើយដំណាក់កាលសមត្ថកិច្ច ចៅក្រមស៊ើបសួរ និងនាពេលសវនាការ ដែលមានន័យប្រហាក់ប្រហែលគ្នាថា៖ កាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០២២ ម៉ោងប្រហែល១១ និង៣០ នាទី ខ្លួនកំពុងតែដេកនៅផ្ទះ ក៏ស្រាប់តែមានសមត្ថកិច្ចចុះមកឃាត់ខ្លួនតែម្តង ។ ពេលសមត្ថកិច្ចឃាត់ខ្លួន ពុំបានដកហូតអ្វីបាននោះទេ ។ ខ្លួនចេះប្រើប្រាស់គ្រឿងញៀនតាមរយៈឈ្មោះ [redacted] ធារិទ្ធ ។ កន្លងមកនៅឆ្នាំ២០១៨ ខ្លួនធ្លាប់ជាប់ពន្ធនាគារចំនួន០២ឆ្នាំ និងបានចេញវិញនៅថ្ងៃទី០៨ ខែមករា ឆ្នាំ២០២០ ចាប់តាំងពីពេលនោះមកមិនដែលពាក់ព័ន្ធរឿងគ្រឿងញៀនអ្វីទេ ។ ក្រោយមកនៅអំឡុងខែធ្នូ ឆ្នាំ២០២១ ក៏ចាប់ផ្តើមប្រើប្រាស់វិញ ដោយទិញថ្នាំញៀនពីឈ្មោះ [redacted] ចាន់ឌីណា ទិញចំនួន០៣ដង ដោយទិញម្តងៗតម្លៃ៥ម៉ឺនរៀល បានចំនួន០១កញ្ចប់តូច ហើយយកមកប្រើប្រាស់ជាមួយឈ្មោះ ដា អេទស្រី ត្រូវជាសង្សាររបស់ឈ្មោះ [redacted] ចាន់ឌីណា ។ ក្រោយមកទៀត ខ្លួនក៏ធ្លាប់បានទិញថ្នាំញៀនពីឈ្មោះ [redacted] សីហា បាន០១ដង តម្លៃ៥ម៉ឺនរៀល យកមកប្រើជាមួយគ្នាតែម្តង និងធ្លាប់ប្រើប្រាស់ជាមួយឈ្មោះ [redacted] សីហា និងឈ្មោះ [redacted] ម៉ាឡែន ចំនួន០៣ដង ។ កន្លងមកតាំងពីខ្លួនចេញពីពន្ធនាគារមក ខ្លួនមិនដែលលក់ ឬចែកចាយថ្នាំញៀនឱ្យនរណាទេ តែបើខ្លួនប្រើប្រាស់ថ្នាំញៀនខ្លួនប្រើប្រាស់មែន ។ នៅពេលសមត្ថកិច្ចឃាត់ខ្លួន ខ្លួនបានសហការជាមួយប៉ូលីសចាប់ឈ្មោះ [redacted] សីហា និងឈ្មោះ [redacted] ចាន់ឌីណា បាន ។

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សីហា បានឆ្លើយនៅដំណាក់កាលសមត្ថកិច្ច ចៅក្រមស៊ើបសួរ និងនាពេលសវនាការ ដែលមានន័យប្រហាក់ប្រហែលគ្នាថា៖ កាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០២២ ខ្លួននៅផ្ទះក៏ត្រូវបានសមត្ថកិច្ចឃាត់ខ្លួន និងដកហូតបានឧបករណ៍សម្រាប់ជក់ថ្នាំញៀនមួយចំនួន ថ្នាំញៀនចំនួន០១កញ្ចប់ និងទូរស័ព្ទដៃចំនួន០១គ្រឿង ។ កន្លងមកខ្លួនធ្លាប់ប្រើប្រាស់ថ្នាំញៀនបានប្រហែល១០ឆ្នាំមកហើយ និងបានឈប់ប្រើប្រាស់ថ្នាំញៀននៅយូរដែរហើយ រហូតដល់ឆ្នាំ២០២២ ខ្លួនបានបន្តប្រើប្រាស់ថ្នាំញៀនបន្តទៀត ដោយថ្នាំញៀនដែលខ្លួនបានប្រើប្រាស់ ខ្លួនទិញពីឈ្មោះ មុំ រស់នៅរាជធានីភ្នំពេញ បានចំនួន១ដង តម្លៃ២ម៉ឺនរៀល យកមកជក់ជាមួយឈ្មោះ [redacted] ម៉ាឡែន ឈ្មោះ ព្រំ រតនា នៅក្នុងផ្ទះរបស់ខ្លួន ដោយបានចូលលុយគ្នាចំនួន២ម៉ឺនរៀល ។ ចំពោះថ្នាំញៀន គឺខ្លួនមិនដែលលក់ទេ គ្រាន់តែទិញយកមកប្រើប្រាស់តែប៉ុណ្ណោះ ។

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ឡុង បានឆ្លើយនៅដំណាក់កាលសមត្ថកិច្ច ចៅក្រមស៊ើបសួរ និងនាពេលសវនាការ ដែលមានន័យប្រហាក់ប្រហែលគ្នាថា៖ កាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០២២ វេលាម៉ោង១០ និង៤៥ នាទីព្រឹក ខ្លួនកំពុងដាក់ទឹកសុទ្ធឱ្យគេ ស្រាប់តែមានសមត្ថកិច្ចមកឃាត់ខ្លួន និងដកហូតទូរស័ព្ទចំនួន០១គ្រឿង ក្រោយមកធ្វើការឆែកឆេររកឃើញថ្នាំញៀនចំនួន០១កញ្ចប់ ។ ខ្លួនចេះប្រើប្រាស់ថ្នាំញៀនតាំងពីអំឡុងឆ្នាំ២០១០ ហើយក៏ឈប់ប្រើប្រាស់វិញបានប្រហែល១០ឆ្នាំ ។ ក្រោយមកអំឡុងឆ្នាំ២០២០ ខ្លួនក៏បានប្រើប្រាស់ថ្នាំញៀនម្តងទៀតជាមួយឈ្មោះ ភិន រស់នៅខេត្តប៉ៃលិន តែមិនដឹងគេទិញនៅណាទេ ។ បន្ទាប់មកក្នុងឆ្នាំ២០២២ ខ្លួនក៏បានស្គាល់ឈ្មោះ [redacted] រតនា ហៅ ប្រជៀវ ហើយក៏បានទិញថ្នាំញៀនពីគាត់បានចំនួន០២ដង ក្នុងម្តងៗតម្លៃ២ម៉ឺនរៀល យកមកជក់តែម្នាក់ឯងនៅកន្លែងធ្វើការ ។ ថ្នាំញៀនដែលខ្លួនប្រើប្រាស់ទិញពីឈ្មោះ [redacted] រតនា ពិតប្រាកដមែន ។

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ធារិទ្ធ បានឆ្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរថា៖ ខ្លួនចេះប្រើប្រាស់ថ្នាំញៀនតាំងពីឆ្នាំ២០១៣ រហូតដល់ចុងឆ្នាំ២០២១ ដោយថ្នាំញៀនដែលខ្លួនប្រើប្រាស់នោះ គឺទិញពីជនមិនស្គាល់ឈ្មោះចំនួន០១ដង ក្នុងម្តងតម្លៃ១០ដុល្លារ ដោយយកមកជក់គ្នាពីរនាក់ នៅក្នុងផ្ទះរបស់ឈ្មោះ [redacted] រតនា ហៅ ប្រជៀវ ។ ចំពោះឈ្មោះ [redacted] រតនា ខ្លួនស្គាល់នៅពេលដែលទៅលេងបុកប៊ីយ៉ែជាមួយគ្នា និងបានប្រើប្រាស់ថ្នាំញៀនជាមួយគ្នា ។ ចំណែកឈ្មោះ [redacted] រតនា ឆ្លើយថាធ្លាប់ចូលលុយគ្នាទិញថ្នាំញៀនមកប្រើប្រាស់ជាមួយខ្លួន គឺមិនពិតឡើយ ដោយសារខ្លួនជាអ្នកចេញលុយខ្លួនឯង ហើយយកថ្នាំញៀនមកជក់ជាមួយឈ្មោះ [redacted] រតនា ប៉ុណ្ណោះ ។ ខ្លួនពិតជាស្គាល់ឈ្មោះ [redacted] រតនា ហៅ ប្រជៀវ និងធ្លាប់បានប្រើប្រាស់ថ្នាំញៀនជាមួយគ្នាប្រាកដមែន ។

-តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] សភារ៉ា (មន្ត្រីនគរបាលយុត្តិធម៌) បានឆ្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរ និងនាពេលសវនាការថា៖ កាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០២២ វេលាម៉ោង ១១ និង ៤០ នាទីព្រឹក ភ្នាក់ងារផ្តល់ព័ត៌មានបានរាយការណ៍មក សមត្ថកិច្ចថា នៅចំណុចភូមិមេភ្លើង សង្កាត់ស្វាយរៀង ក្រុងស្វាយរៀង មានមុខសញ្ញាកំពុងធ្វើសកម្មភាពជួញដូរ និងប្រើប្រាស់គ្រឿងញៀន ។ ក្រោយទទួលព័ត៌មានភ្លាម កម្លាំងជំនាញខេត្ត សហការជាមួយកម្លាំងអធិការនគរបាលក្រុងស្វាយរៀង ធ្វើការស្រាវជ្រាវឈានដល់ការឃាត់ខ្លួនជនសង្ស័យជាបន្តបន្ទាប់ចំនួន០៧នាក់ ដកហូតបានថ្នាំញៀនចំនួន០៥កញ្ចប់ ទូរស័ព្ទចំនួន០៧គ្រឿង ម៉ូតូចំនួន០២គ្រឿង រួចនាំយកមកការិយាល័យ ប្រឆាំងគ្រឿងញៀនដើម្បីសាកសួរបំភ្លឺ និងធ្វើតេស្តទឹកម៉ូត្រ លទ្ធផលវិជ្ជមានទាំង០៧នាក់ ។ ខ្លួនសូមបញ្ជាក់ថា ក្នុងប្រតិបត្តិការនេះ ក្នុងចំណោមជនសង្ស័យចំនួន០៧នាក់ គឺក្នុងនោះមានមុខសញ្ញារឹងរូស និងបានតដៃជាមួយសមត្ថកិច្ច ហើយសមត្ថកិច្ចបានប្រើសិទ្ធិការពារខ្លួន ឈានដល់ការផ្ទុះអាវុធចំនួន០៣គ្រាប់ (បាញ់ឡើងលើ) ។ ក្រោយធ្វើការសាកសួរចម្លើយជនសង្ស័យឈ្មោះ [redacted] រតនា ហៅ ប្រជៀវ បានបញ្ជាក់ថា ខ្លួនធ្លាប់ទិញថ្នាំញៀនពីឈ្មោះ [redacted] ចាន់ឌីណា និងដោយមានការសម្របសម្រួលនីតិវិធីដោយលោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តស្វាយរៀង បានអនុញ្ញាតឲ្យសមត្ថកិច្ចធ្វើការឃាត់ខ្លួនជនសង្ស័យបន្ថែមចំនួន០២នាក់ទៀត ធ្វើការដកហូតថ្នាំញៀនចំនួន១១កញ្ចប់ ទូរស័ព្ទដៃ០២គ្រឿង ម៉ូតូចំនួន០៤គ្រឿង និងបានធ្វើតេស្តទឹកម៉ូត្រ ជាលទ្ធផលវិជ្ជមានសារធាតុញៀន រួចក៏បានកសាង សំណុំរឿង រួមទាំងវត្ថុតាងបញ្ជូនមកតុលាការចាត់ការនីតិវិធីបន្ត។ សមត្ថកិច្ចសូមបញ្ជាក់ថា ជនសង្ស័យទាំង០៩នាក់នេះ សុទ្ធតែមុខសញ្ញាចាស់ ដែលប្រព្រឹត្តមិនរាងចាលកន្លងមក ។ ចំពោះការសួរចម្លើយលើជនសង្ស័យ គឺសមត្ថកិច្ចបានអនុវត្តតាមនីតិវិធីច្បាប់ មិនមានការបង្ខិតបង្ខំ ឬដោះដូរឲ្យឆ្លើយសារភាពដើម្បីរួចពីការចោទប្រកាន់នោះទេ ។

-តាមចម្លើយរបស់ជនជាប់ចោទ និងចម្លើយរបស់សាក្សី ព្រមទាំងរបាយការណ៍សំយោគរបស់មន្ត្រីនគរបាលយុត្តិធម៌ គឺមានភាពស៊ីសង្វាក់គ្នាយ៉ាងខ្លាំងទៅនឹងភស្តុតាងក្នុងសំណុំរឿង ដែលបញ្ជាក់បានថា៖ ជនជាប់ចោទឈ្មោះ [redacted] លីស៊ីថន ពិតជាបានប្រព្រឹត្តបទល្មើស ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅក្នុងក្រុងស្វាយរៀង ខេត្តស្វាយរៀង កាលពីអំឡុងឆ្នាំ២០១២ រហូតដល់ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៣ និងទី៥ និងមាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ ជនជាប់ចោទឈ្មោះ [redacted] ចន្ថា ឈ្មោះ [redacted] សីហា ឈ្មោះ [redacted] រតនា ឈ្មោះ [redacted] ឡុង ឈ្មោះ [redacted] ដារ៉ា និងឈ្មោះ [redacted] ចាន់ឌីណា ពិតជាបានប្រព្រឹត្តបទល្មើស ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅក្នុងក្រុងស្វាយរៀង ខេត្តស្វាយរៀង កាលពីអំឡុងឆ្នាំ២០១២ រហូតដល់ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៣ និងទី៤ និងមាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ ជនជាប់ចោទឈ្មោះ [redacted] សុចិន្តា ពិតជាបានប្រព្រឹត្តបទល្មើស ចាត់ចែងឲ្យប្រើប្រាស់ និងប្រើ

ប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅក្នុងក្រុងស្វាយរៀង ខេត្តស្វាយរៀង កាលពីអំឡុងឆ្នាំ២០១២ រហូតដល់ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤២ កថាខណ្ឌទី១ និងទី២ និងមាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ ជនជាប់ចោទឈ្មោះ [redacted] ធារិទ្ធ ពិតជាបានប្រព្រឹត្តបទល្មើស **ចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅក្នុងក្រុងស្វាយរៀង ខេត្តស្វាយរៀង កាលពីអំឡុងឆ្នាំ២០១២ រហូតដល់ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤២ កថាខណ្ឌទី១ និងទី២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ ជនជាប់ចោទឈ្មោះ [redacted] ម៉ាឡែន ពិតជាបានប្រព្រឹត្តបទល្មើស **ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅក្នុងក្រុងស្វាយរៀង ខេត្តស្វាយរៀង កាលពីអំឡុងឆ្នាំ២០១២ រហូតដល់ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រាកដមែន ។

-**យល់ឃើញពីសេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ** បានប្តឹងសុំរក្សាបទចោទ និងតម្កល់ដីកាសន្និដ្ឋានស្ថាពររបស់តំណាងអយ្យការទុកជាបានការដដែល និងប្តឹងសុំក្រុមប្រឹក្សាជំនុំជម្រះផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] **លីស៊ីថន** ពីបទ **ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅក្នុងក្រុងស្វាយរៀង ខេត្តស្វាយរៀង កាលពីអំឡុងឆ្នាំ២០១២ រហូតដល់ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៣ និងទី៥ និងមាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ ជនជាប់ចោទឈ្មោះ [redacted] ចន្ថា ឈ្មោះ [redacted] សីហា ឈ្មោះ [redacted] រតនា ឈ្មោះ [redacted] ឡុង ឈ្មោះ [redacted] ដារ៉ា និងឈ្មោះ [redacted] ចាន់ឌីណា ពីបទ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅក្នុងក្រុងស្វាយរៀង ខេត្តស្វាយរៀង កាលពីអំឡុងឆ្នាំ២០១២ រហូតដល់ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៣ និងទី៤ និងមាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ ជនជាប់ចោទឈ្មោះ [redacted] សុចិន្តា ពីបទ **ចាត់ចែងឱ្យប្រើប្រាស់ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅក្នុងក្រុងស្វាយរៀង ខេត្តស្វាយរៀង កាលពីអំឡុងឆ្នាំ២០១២ រហូតដល់ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤២ កថាខណ្ឌទី១ និងទី២ និងមាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ ជនជាប់ចោទឈ្មោះ [redacted] ធារិទ្ធ ពីបទ **ចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅក្នុងក្រុងស្វាយរៀង ខេត្តស្វាយរៀង កាលពីអំឡុងឆ្នាំ២០១២ រហូតដល់ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤២ កថាខណ្ឌទី១ និងទី២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ ជនជាប់ចោទឈ្មោះ [redacted] ម៉ាឡែន ពីបទ **ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅក្នុងក្រុងស្វាយរៀង ខេត្តស្វាយរៀង កាលពីអំឡុងឆ្នាំ២០១២ រហូតដល់ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ ការប្តឹងសុំរបស់តំណាងអយ្យការមានភាពសមរម្យ ដែលអាចឱ្យតុលាការពិចារណាសម្រេចបាន ។

-**យល់ឃើញពី ធាតុផ្សំនៃបទល្មើស៖**

ក.១-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] លីស៊ីថន គឺជាបទល្មើស **ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌទី៣ និងទី៥ និងមាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

ក.២-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ចន្ថា ឈ្មោះ [redacted] សីហា ឈ្មោះ [redacted] រតនា ឈ្មោះ [redacted] ឡុង ឈ្មោះ [redacted] ដារ៉ា និងឈ្មោះ [redacted] ចាន់ឌីណា គឺជាបទល្មើស ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌទី៣ និងទី៤ និងមាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

ក.៣-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] សុចិន្តា គឺជាបទល្មើស ចាត់ចែងឱ្យប្រើប្រាស់ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤២ កថាខណ្ឌទី១ និងទី២ និងមាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

ក.៤-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ធារិទ្ធ គឺជាបទល្មើស ចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤២ កថាខណ្ឌទី១ និងទី២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

ក.៥-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ម៉ាឡែន គឺជាបទល្មើស ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

ខ.១-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] លីស៊ីថន បានធ្វើឱ្យប៉ះពាល់ដល់សន្តិសុខសណ្តាប់ធ្នាប់ របៀបរៀបរយសង្គម ប៉ះពាល់ដល់ផលប្រយោជន៍របស់ប្រជាពលរដ្ឋ ជាពិសេសច្បាប់បញ្ញត្តិអំពើនេះ ជាបទល្មើស ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដែលជាអំពើបំពានលើច្បាប់ដូចមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៣ និងទី៥ និងមាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

ខ.២-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ចន្ថា ឈ្មោះ [redacted] សីហា ឈ្មោះ [redacted] រតនា ឈ្មោះ [redacted] ឡុង ឈ្មោះ [redacted] ដារ៉ា និងឈ្មោះ [redacted] ចាន់ឌីណា បានធ្វើឱ្យប៉ះពាល់ដល់សន្តិសុខសណ្តាប់ធ្នាប់ របៀបរៀបរយសង្គម ប៉ះពាល់ដល់ផលប្រយោជន៍របស់ប្រជាពលរដ្ឋ ជាពិសេសច្បាប់បញ្ញត្តិអំពើនេះ ជាបទល្មើស ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដែលជាអំពើបំពានលើច្បាប់ដូចមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៣ និងទី៤ និងមាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

ខ.៣-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] សុចិន្តា បានធ្វើឱ្យប៉ះពាល់ដល់សន្តិសុខសណ្តាប់ធ្នាប់ របៀបរៀបរយសង្គម ប៉ះពាល់ដល់ផលប្រយោជន៍របស់ប្រជាពលរដ្ឋ ជាពិសេសច្បាប់បញ្ញត្តិអំពើនេះ ជាបទល្មើស ចាត់ចែងឱ្យប្រើប្រាស់ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដែលជាអំពើបំពានលើច្បាប់ដូចមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤២ កថាខណ្ឌទី១ និងទី២ និងមាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

ខ.៤-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ធារិទ្ធ បានធ្វើឱ្យប៉ះពាល់ដល់សន្តិសុខសណ្តាប់ធ្នាប់ របៀបរៀបរយសង្គម ប៉ះពាល់ដល់ផលប្រយោជន៍របស់ប្រជាពលរដ្ឋ ជាពិសេសច្បាប់បញ្ញត្តិអំពើនេះ ជាបទល្មើស ចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដែលជាអំពើបំពានលើច្បាប់ដូចមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤២ កថាខណ្ឌទី១ និងទី២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

ខ.៥-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ម៉ាឡែន បានធ្វើឱ្យប៉ះពាល់ដល់សន្តិសុខសណ្តាប់ធ្នាប់ របៀបរៀបរយសង្គម ប៉ះពាល់ដល់ផលប្រយោជន៍របស់ប្រជាពលរដ្ឋ ជាពិសេសច្បាប់បញ្ញត្តិអំពើនេះ ជាបទល្មើស ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដែលជាអំពើបំពានលើច្បាប់ដូចមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ល។



Scanned with CamScanner

គ.១-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] លីស៊ីថន មានចេតនាទុច្ចរិត ក្នុងការប្រព្រឹត្តបទល្មើស ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដែលជាបទល្មើសព្រហ្មទណ្ឌមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៣ និងទី៥ និងមាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

គ.២-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ចន្ថា ឈ្មោះ [redacted] សីហា ឈ្មោះ [redacted] រតនា ឈ្មោះ [redacted] ឡុង ឈ្មោះ [redacted] ដារ៉ា និងឈ្មោះ [redacted] ចាន់ឌីណា មានចេតនាទុច្ចរិត ក្នុងការប្រព្រឹត្តបទល្មើស ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដែលជាបទល្មើសព្រហ្មទណ្ឌមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៣ និងទី៤ និងមាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

គ.៣-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] សុចិន្តា មានចេតនាទុច្ចរិត ក្នុងការប្រព្រឹត្តបទល្មើស ចាត់ចែងឱ្យប្រើប្រាស់ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដែលជាបទល្មើសព្រហ្មទណ្ឌមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤២ កថាខណ្ឌទី១ និងទី២ និងមាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

គ.៤-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ធារិទ្ធ មានចេតនាទុច្ចរិត ក្នុងការប្រព្រឹត្តបទល្មើស ចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដែលជាបទល្មើសព្រហ្មទណ្ឌមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤២ កថាខណ្ឌទី១ និងទី២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

គ.៥-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ម៉ាឡែន មានចេតនាទុច្ចរិត ក្នុងការប្រព្រឹត្តបទល្មើស ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដែលជាបទល្មើសព្រហ្មទណ្ឌមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

-យល់ឃើញពីសមត្ថភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌៈ តាមនីតិវិធីនៅដំណាក់កាលសមត្ថកិច្ច ដំណាក់កាលអយ្យការ ដំណាក់កាលចៅក្រមស៊ើបសួរ និងនាពេលសវនាការ ឃើញថា ជនជាប់ចោទទាំងអស់ខាងលើ គឺជានីតិជន មានស្មារតីគ្រប់គ្រាន់ដោយពុំមានសញ្ញាណណាមួយបញ្ជាក់មានបញ្ហាវិបល្លាសស្មារតីឡើយ ដូច្នេះជនជាប់ចោទត្រូវទទួលខុសត្រូវចំពោះអំពើដែលខ្លួនបានប្រព្រឹត្ត ។

-យល់ឃើញថា ជនជាប់ចោទឈ្មោះ [redacted] ចន្ថា ឈ្មោះ [redacted] សីហា ឈ្មោះ [redacted] រតនា ឈ្មោះ [redacted] ឡុង ឈ្មោះ [redacted] ដារ៉ា ឈ្មោះ [redacted] ចាន់ឌីណា ឈ្មោះ [redacted] សុចិន្តា ឈ្មោះ [redacted] ធារិទ្ធ និងឈ្មោះ [redacted] ម៉ាឡែន មានការយល់ដឹងតិចតួច មានជីវភាពក្រលំបាក បានស្នើសុំតុលាការបន្ធូរបន្ថយទោស ហើយបរិមាណគ្រឿងញៀនដែលដកហូតបានពីជនជាប់ចោទមានបរិមាណតិចតួច ហើយជនជាប់ចោទខ្លះក៏ពុំមានដកហូតបានគ្រឿងញៀននោះដែរ ។ ចំណែកជនជាប់ចោទឈ្មោះ [redacted] លីស៊ីថន បានឆ្លើយបដិសេធការចោទប្រកាន់ ពុំមានការភ្ញាក់រលឹកដឹងកំហុសនោះឡើយ ហើយថ្នាំញៀនដែលដកហូតបានពីជនជាប់ចោទ គឺមានបរិមាណច្រើន ដែលបង្កព្យសនកម្មយ៉ាងធ្ងន់ធ្ងរដល់សង្គម ។ ចេតនា និងអំពើរបស់ជនជាប់ចោទខាងលើ គឺជាការប្រព្រឹត្តបទល្មើសគ្រឿងញៀន ហើយអំពើរបស់ជនជាប់ចោទទាំងអស់ខាងលើធ្វើឱ្យប៉ះពាល់ដល់សង្គមយ៉ាងធ្ងន់ធ្ងរ ដូច្នេះគប្បីតុលាការផ្តន្ទាទោសជនជាប់ចោទឱ្យបានសមស្របទៅតាមអំពើ ទំហំព្យសនកម្ម និងកិរិយាមាយាទរបស់ជនជាប់ចោទ ដូចមានចែងក្នុងមាត្រា ៩៦ នៃក្រមព្រហ្មទណ្ឌ និងគប្បីព្យួរទោសធម្មតាមួយផ្នែកឱ្យជនជាប់ចោទដែលឆ្លើយសារភាពជូនតុលាការ និងពុំមានគ្រឿងញៀនដែលដកហូតបាន តាមមាត្រា ១០៤ និងមាត្រា ១០៨ នៃក្រមព្រហ្មទណ្ឌ ។

-បានឃើញ លទ្ធផលកោសលវិច័យគ្រឿងញៀនលេខ ៣៦០១០/២២ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២២ របស់មន្ទីរពិសោធន៍នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបញ្ជាក់លើសំណាកគ្រឿងញៀនដែល

ដកហូតបានពីជនជាប់ចោទឈ្មោះ [redacted] លីស៊ីថន ថា វិជ្ជមាន, វត្តមានសារធាតុញៀនឈ្មោះ មេតំហ្វេតាមីន (Metamfetamine) ។ សំណាកជាគ្រឿងញៀនប្រភេទក្រាមម្សៅឈ្មោះ **មេតំហ្វេតាមីន**(Metamfetamine) (ហៅក្រៅម៉ាទឹកកក ឬអាយ) ដែលមានកម្រិតភាពសុទ្ធ **៧២.៦០%** (ចិតសិបពីរ កណ្តក់សញ្ញា ហុកសិបភាគរយ) នៃទម្ងន់សរុប ហើយតុលាការគណនារកឃើញបរិមាណកម្រិតធាតុសុទ្ធសរុបគឺ $\frac{៣០.០៨ក្រាម \times ៧២.៦០}{១០០}$ = **២១.៨៤** (**ម្ភៃមួយ កណ្តក់សញ្ញា ប៉ែតសិបបួន**)ក្រាម ជាសារធាតុមេតំហ្វេតាមីន វាស្ថិតក្នុងតារាងទី២ មាត្រា៥ ចំណាត់ថ្នាក់គ្រឿងញៀន ដូចមានចែងលម្អិតក្នុងតារាងឧបសម្ព័ន្ធ ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនកម្ពុជា ។

**-បានឃើញ** លទ្ធផលកោសលវិច័យគ្រឿងញៀនលេខ **៣៦០១១/២២ ម.ព.អ.ជ.ប.គ.ញ** ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២២ របស់មន្ទីរពិសោធន៍នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបញ្ជាក់លើសំណាកគ្រឿងញៀនដែលដកហូតបានពីជនជាប់ចោទឈ្មោះ [redacted] សីហា ថា វិជ្ជមាន, វត្តមានសារធាតុញៀនឈ្មោះ មេតំហ្វេតាមីន (Metamfetamine) ។ សំណាកជាគ្រឿងញៀនប្រភេទក្រាមម្សៅឈ្មោះ **មេតំហ្វេតាមីន**(Metamfetamine) (ហៅក្រៅម៉ាទឹកកក ឬអាយ) ដែលមានកម្រិតភាពសុទ្ធ **៧២.៦០%** (ចិតសិបពីរ កណ្តក់សញ្ញា ហុកសិបភាគរយ) នៃទម្ងន់សរុប ហើយតុលាការគណនារកឃើញបរិមាណកម្រិតធាតុសុទ្ធសរុបគឺ $\frac{៣.៦៧ក្រាម \times ៧២.៦០}{១០០}$ = **២.៦៦** (**ពីរ កណ្តក់សញ្ញា ហុកសិបប្រាំមួយ**)ក្រាម ជាសារធាតុមេតំហ្វេតាមីន វាស្ថិតក្នុងតារាងទី២ មាត្រា៥ ចំណាត់ថ្នាក់គ្រឿងញៀន ដូចមានចែងលម្អិតក្នុងតារាងឧបសម្ព័ន្ធ ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនកម្ពុជា ។

**-បានឃើញ** លទ្ធផលកោសលវិច័យគ្រឿងញៀនលេខ **៣៦០១២/២២ ម.ព.អ.ជ.ប.គ.ញ** ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២២ របស់មន្ទីរពិសោធន៍នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបញ្ជាក់លើសំណាកគ្រឿងញៀនដែលដកហូតបានពីជនជាប់ចោទឈ្មោះ [redacted] ចាន់ឌីណា ថា វិជ្ជមាន, វត្តមានសារធាតុញៀនឈ្មោះ មេតំហ្វេតាមីន (Metamfetamine) ។ សំណាកជាគ្រឿងញៀនប្រភេទក្រាមម្សៅឈ្មោះ **មេតំហ្វេតាមីន**(Metamfetamine) (ហៅក្រៅម៉ាទឹកកក ឬអាយ) ដែលមានកម្រិតភាពសុទ្ធ **៧២.៦០%** (ចិតសិបពីរ កណ្តក់សញ្ញា ហុកសិបភាគរយ) នៃទម្ងន់សរុប ហើយតុលាការគណនារកឃើញបរិមាណកម្រិតធាតុសុទ្ធសរុបគឺ $\frac{០.៩៦ក្រាម \times ៧២.៦០}{១០០}$ = **០.៦៩** (**សូន្យ កណ្តក់សញ្ញា ហុកសិបប្រាំបួន**)ក្រាម ជាសារធាតុមេតំហ្វេតាមីន វាស្ថិតក្នុងតារាងទី២ មាត្រា៥ ចំណាត់ថ្នាក់គ្រឿងញៀន ដូចមានចែងលម្អិតក្នុងតារាងឧបសម្ព័ន្ធ ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនកម្ពុជា ។

**-បានឃើញ** លទ្ធផលកោសលវិច័យគ្រឿងញៀនលេខ **៣៦០១៣/២២ ម.ព.អ.ជ.ប.គ.ញ** ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២២ របស់មន្ទីរពិសោធន៍នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបញ្ជាក់លើសំណាកគ្រឿងញៀនដែលដកហូតបានពីជនជាប់ចោទឈ្មោះ [redacted] ដារ៉ា ថា វិជ្ជមាន, វត្តមានសារធាតុញៀនឈ្មោះ មេតំហ្វេតាមីន (Metamfetamine) ។ សំណាកជាគ្រឿងញៀនប្រភេទក្រាមម្សៅឈ្មោះ **មេតំហ្វេតាមីន**(Metamfetamine) (ហៅក្រៅម៉ាទឹកកក ឬអាយ) ដែលមានកម្រិតភាពសុទ្ធ **៧២.៦០%** (ចិតសិបពីរ កណ្តក់សញ្ញា ហុកសិបភាគរយ) នៃទម្ងន់សរុប ហើយតុលាការគណនារកឃើញបរិមាណកម្រិតធាតុសុទ្ធសរុបគឺ $\frac{០.១៦ក្រាម \times ៧២.៦០}{១០០}$ = **០.១១** (**សូន្យ កណ្តក់សញ្ញា ដប់មួយ**)ក្រាម ជាសារធាតុមេតំហ្វេតាមីន វាស្ថិតក្នុងតារាងទី២ មាត្រា៥ ចំណាត់ថ្នាក់គ្រឿងញៀន ដូចមានចែងលម្អិតក្នុងតារាងឧបសម្ព័ន្ធ ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនកម្ពុជា ។

**-បានឃើញ** លទ្ធផលកោសលវិច័យគ្រឿងញៀនលេខ **៣៦០១៤/២២ ម.ព.អ.ជ.ប.គ.ញ** ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២២ របស់មន្ទីរពិសោធន៍នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបញ្ជាក់លើសំណាកគ្រឿងញៀនដែល



Scanned with CamScanner

ដកហូតបានពីជនជាប់ចោទឈ្មោះ [redacted] ចន្ថា ថា វិជ្ជមាន, វត្ថុមានសារធាតុញៀនឈ្មោះ **មេតំហ្វេតាមីន** (Metamfetamine) ។ សំណាកជាគ្រឿងញៀនប្រភេទក្រាមម្សៅឈ្មោះ **មេតំហ្វេតាមីន**(Metamfetamine) (ហៅក្រៅម៉ាទឹកកក ឬអាយ) ដែលមានកម្រិតភាពសុទ្ធ ៧២.៦០% (ចិតសិបពីរ កណ្តក់សញ្ញា ហុកសិបភាគរយ) នៃទម្ងន់សរុប ហើយតុលាការគណនារកឃើញបរិមាណកម្រិតធាតុសុទ្ធសរុបគឺ $\frac{\text{៤.៤០ក្រាម}\times\text{៧២.៦០}}{\text{១០០}} = \text{៣.១៩}$ (បី កណ្តក់សញ្ញា ដប់ប្រាំបួន)ក្រាម ជាសារធាតុមេតំហ្វេតាមីន ស្ថិតក្នុងតារាងទី២ មាត្រា៥ ចំណាត់ថ្នាក់គ្រឿងញៀន ដូចមានចែងលម្អិតក្នុងតារាងឧបសម្ព័ន្ធ ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនកម្ពុជា ។

**-បានឃើញ** លទ្ធផលកោសលវិច័យគ្រឿងញៀនលេខ **៣៦០១៥/២២ ម.ព.អ.ជ.ប.គ.ញ** ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២២ របស់មន្ទីរពិសោធន៍នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបញ្ជាក់លើសំណាកគ្រឿងញៀនដែលដកហូតបានពីជនជាប់ចោទឈ្មោះ [redacted] **ឡុង** ថា វិជ្ជមាន, វត្ថុមានសារធាតុញៀនឈ្មោះ **មេតំហ្វេតាមីន** (Metamfetamine) ។ សំណាកជាគ្រឿងញៀនប្រភេទក្រាមម្សៅឈ្មោះ **មេតំហ្វេតាមីន**(Metamfetamine) (ហៅក្រៅម៉ាទឹកកក ឬអាយ) ដែលមានកម្រិតភាពសុទ្ធ ៧២.៦០% (ចិតសិបពីរ កណ្តក់សញ្ញា ហុកសិបភាគរយ) នៃទម្ងន់សរុប ហើយតុលាការគណនារកឃើញបរិមាណកម្រិតធាតុសុទ្ធសរុបគឺ $\frac{\text{០.០៨ក្រាម}\times\text{៧២.៦០}}{\text{១០០}} = \text{០.០៥}$ (សូន្យ កណ្តក់សញ្ញា សូន្យប្រាំ)ក្រាម ជាសារធាតុមេតំហ្វេតាមីន ស្ថិតក្នុងតារាងទី២ មាត្រា៥ ចំណាត់ថ្នាក់គ្រឿងញៀន ដូចមានចែងលម្អិតក្នុងតារាងឧបសម្ព័ន្ធ ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនកម្ពុជា ។

**-បានឃើញ** លទ្ធផលកោសលវិច័យគ្រឿងញៀនលេខ **៣៦០១៦/២២ ម.ព.អ.ជ.ប.គ.ញ** ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២២ របស់មន្ទីរពិសោធន៍នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបញ្ជាក់លើសំណាកគ្រឿងញៀនដែលដកហូតបានពីជនជាប់ចោទឈ្មោះ [redacted] សុចិន្តា ថា វិជ្ជមាន, វត្ថុមានសារធាតុញៀនឈ្មោះ **មេតំហ្វេតាមីន** (Metamfetamine) ។ សំណាកជាគ្រឿងញៀនប្រភេទក្រាមម្សៅឈ្មោះ **មេតំហ្វេតាមីន**(Metamfetamine) (ហៅក្រៅម៉ាទឹកកក ឬអាយ) ដែលមានកម្រិតភាពសុទ្ធ ៧២.៦០% (ចិតសិបពីរ កណ្តក់សញ្ញា ហុកសិបភាគរយ) នៃទម្ងន់សរុប ហើយតុលាការគណនារកឃើញបរិមាណកម្រិតធាតុសុទ្ធសរុបគឺ $\frac{\text{០.០៦ក្រាម}\times\text{៧២.៦០}}{\text{១០០}} = \text{០.០៤}$ (សូន្យ កណ្តក់សញ្ញា សូន្យបួន)ក្រាម ជាសារធាតុមេតំហ្វេតាមីន ស្ថិតក្នុងតារាងទី២ មាត្រា៥ ចំណាត់ថ្នាក់គ្រឿងញៀន ដូចមានចែងលម្អិតក្នុងតារាងឧបសម្ព័ន្ធ ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនកម្ពុជា ។

**-យល់ឃើញថា** វត្ថុចាប់យកដូចមានក្នុងកំណត់ហេតុទទួលវត្ថុចាប់យកលេខ ១៨ អ.យ.ឃ/២២ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០២២ រួមមាន៖ ទូរស័ព្ទដៃចំនួន០៨(ប្រាំបី)គ្រឿង គឺ ម៉ាក VIVO ពណ៌ខ្មៅចំនួន០២គ្រឿង ម៉ាក OPPO ពណ៌ខ្មៅលាយក្រហមចំនួន០១គ្រឿង ម៉ាក Realme ពណ៌ខ្មៅលាយទឹកសមុទ្រចំនួន០១គ្រឿង ម៉ាក Mi ពណ៌ខ្មៅលាយទឹកប្រាក់ចំនួន០១គ្រឿង ម៉ាក NOKIA ពណ៌ខ្មៅលាយទឹកប៊ិចចំនួន០១គ្រឿង ម៉ាក SAMSUNG ពណ៌ខ្មៅលាយទឹកប្រាក់ចំនួន០១គ្រឿង និងម៉ាក OPPO ពណ៌ខ្មៅចំនួន០១គ្រឿង ។ ម៉ូតូចំនួន០២(ពីរ)គ្រឿង គឺ ម៉ាក HONDA C125 ពណ៌ខ្មៅ លេខម៉ាស៊ីន ND125ME-9116970 ពាក់ស្លាកលេខ ស្វាយរៀង 1D-7537 ចំនួន០១គ្រឿង និងម៉ាក SUZUKI VIVA ពណ៌ខ្មៅ លេខម៉ាស៊ីន BE4CC-TH349239 ពាក់ស្លាកលេខ ភ្នំពេញ 1AE-2610 ចំនួន០១គ្រឿង ។ វត្ថុចាប់យកដូចមានក្នុងដីកាសម្រេចឱ្យរក្សាទុកវត្ថុចាប់យកលេខ ៤០២ តក.ព្រទ/២២ ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២២ រួមមាន៖ ស្រោមសំបុត្រពណ៌គគីរបិទជិតមានបិទស្លាកបញ្ជាក់ចំនួន០៥(ប្រាំ)កញ្ចប់ ដែលក្នុងនោះមាន០៣កញ្ចប់ មានផ្ទុកសារធាតុញៀនសម្រាប់ប្រតិកោសលវិច័យរបស់ឈ្មោះ [redacted] លីស៊ីថន ឈ្មោះ [redacted] ចន្ថា និងឈ្មោះ [redacted] សីហា និង០២កញ្ចប់ មានផ្ទុក



Scanned with CamScanner

សារធាតុញៀន ដែលនៅសល់ដាក់ស្ដែងក្រោយពីដកសំណាកធ្វើកោសលវិច័យ និងប្រតិកោសលវិច័យរបស់ឈ្មោះ ហុង លីស៊ីថន និងឈ្មោះ [redacted] ចន្ថា គឺជាវត្ថុឧបករណ៍ដែលជនជាប់ចោទប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើស និងជាគ្រឿងញៀនដែលត្រូវរឹបអូសដាច់ខាតនោះ គប្បីតុលាការរឹបអូសទុកជាទ្រព្យសម្បត្តិរដ្ឋ និងបំផ្លាញចោល ដោយយោងតាមបញ្ញត្តិមាត្រា ៩៣ និងមាត្រា ៩៤ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

-មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] លីស៊ីថន ពីបទ **ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅក្នុងក្រុងស្វាយរៀង ខេត្តស្វាយរៀង កាលពីអំឡុងឆ្នាំ២០១២ រហូតដល់ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៣ និងទី៥ និងមាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

-មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ចន្ថា ឈ្មោះ [redacted] សីហា ឈ្មោះ [redacted] រតនា ឈ្មោះ [redacted] ឡុង ឈ្មោះ [redacted] ដារ៉ា និងឈ្មោះ [redacted] ចាន់នីណា ពីបទ **ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅក្នុងក្រុងស្វាយរៀង ខេត្តស្វាយរៀង កាលពីអំឡុងឆ្នាំ២០១២ រហូតដល់ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៣ និងទី៤ និងមាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

-មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] សុចិន្ដា ពីបទ **ចាត់ចែងឱ្យប្រើប្រាស់ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅក្នុងក្រុងស្វាយរៀង ខេត្តស្វាយរៀង កាលពីអំឡុងឆ្នាំ២០១២ រហូតដល់ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤២ កថាខណ្ឌទី១ និងទី២ និងមាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

-មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ធារិទ្ធ ពីបទ **ចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅក្នុងក្រុងស្វាយរៀង ខេត្តស្វាយរៀង កាលពីអំឡុងឆ្នាំ២០១២ រហូតដល់ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤២ កថាខណ្ឌទី១ និងទី២ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

-មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ម៉ាឡែន ពីបទ **ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅក្នុងក្រុងស្វាយរៀង ខេត្តស្វាយរៀង កាលពីអំឡុងឆ្នាំ២០១២ រហូតដល់ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

## ហេតុដូច្នេះសម្រេច

១-ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] **លីស៊ីថន** ភេទប្រុស អាយុ២៨ឆ្នាំ ជនជាតិខ្មែរ ជានីតិជន (មានសាវតារជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់ ៨(**ប្រាំបី**)**ឆ្នាំ** និងពិន័យជាប្រាក់ចំនួន **១០.០០០.០០០ (ដប់លាន)**រៀល ពីបទ **ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅក្នុងក្រុងស្វាយរៀង ខេត្តស្វាយរៀង កាលពីអំឡុងឆ្នាំ២០១២ រហូតដល់ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៣ និងទី៥ និងមាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

២-ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] ចន្ថា ភេទប្រុស អាយុ២៩ឆ្នាំ ជនជាតិខ្មែរ ជាទីតិជន (មានសាវតារជាតិដូចខាងលើ) និងឈ្មោះ [redacted] សីហា ហៅ ប្រុស ភេទប្រុស អាយុ៣២ឆ្នាំ ជនជាតិខ្មែរ ជាទីតិជន (មានសាវតារជាតិដូចខាងលើ) ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់ ២(ពីរ)ឆ្នាំ ៦(ប្រាំមួយ)ខែ ពីបទ **ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅក្នុងក្រុងស្វាយរៀង ខេត្តស្វាយរៀង កាលពីអំឡុងឆ្នាំ២០១២ រហូតដល់ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៣ និងទី៤ និងមាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៣-ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] រតនា ហៅ ប្រជៀវ ភេទប្រុស អាយុ២៤ឆ្នាំ ជនជាតិខ្មែរ ជាទីតិជន (មានសាវតារជាតិដូចខាងលើ) ឈ្មោះ [redacted] ឡុង ភេទប្រុស អាយុ៣២ឆ្នាំ ជនជាតិខ្មែរ ជាទីតិជន (មានសាវតារជាតិដូចខាងលើ) ឈ្មោះ [redacted] ដារ៉ា ហៅ ឈុយ ភេទប្រុស អាយុ២៤ឆ្នាំ ជនជាតិខ្មែរ ជាទីតិជន (មានសាវតារជាតិដូចខាងលើ) និងឈ្មោះ [redacted] ចាន់ឌីណា ភេទប្រុស អាយុ២២ឆ្នាំ ជនជាតិខ្មែរ ជាទីតិជន (មានសាវតារជាតិដូចខាងលើ) ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់ ២(ពីរ)ឆ្នាំ តែទោសនេះត្រូវអនុវត្តក្នុងពន្ធនាគាររយៈពេល ១(មួយ)ឆ្នាំ ៦(ប្រាំមួយ)ខែ ទោសសល់ពីនេះព្យួរធម្មតា ពីបទ **ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅក្នុងក្រុងស្វាយរៀង ខេត្តស្វាយរៀង កាលពីអំឡុងឆ្នាំ២០១២ រហូតដល់ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៣ និងទី៤ និងមាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៤-ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] សុចិន្តា ភេទប្រុស អាយុ២៣ឆ្នាំ ជនជាតិខ្មែរ ជាទីតិជន (មានសាវតារជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់ ២(ពីរ)ឆ្នាំ តែទោសនេះត្រូវអនុវត្តក្នុងពន្ធនាគាររយៈពេល ១(មួយ)ឆ្នាំ ៦(ប្រាំមួយ)ខែ ទោសសល់ពីនេះព្យួរធម្មតា ពីបទ **ចាត់ចែងឲ្យប្រើប្រាស់ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅក្នុងក្រុងស្វាយរៀង ខេត្តស្វាយរៀង កាលពីអំឡុងឆ្នាំ២០១២ រហូតដល់ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤២ កថាខណ្ឌទី១ និងទី២ និងមាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៥-ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] ធារិទ្ធ ភេទប្រុស អាយុ២៥ឆ្នាំ ជនជាតិខ្មែរ ជាទីតិជន (មានសាវតារជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់ ២(ពីរ)ឆ្នាំ តែទោសនេះត្រូវព្យួរធម្មតា ពីបទ **ចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅក្នុងក្រុងស្វាយរៀង ខេត្តស្វាយរៀង កាលពីអំឡុងឆ្នាំ២០១២ រហូតដល់ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤២ កថាខណ្ឌទី១ និងទី២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៦-ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] ម៉ាឡែន ភេទប្រុស អាយុ៣២ឆ្នាំ ជនជាតិខ្មែរ ជាទីតិជន (មានសាវតារជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់ ៦(ប្រាំមួយ)ខែ ពីបទ **ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅក្នុងក្រុងស្វាយរៀង ខេត្តស្វាយរៀង កាលពីអំឡុងឆ្នាំ២០១២ រហូតដល់ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។



Scanned with CamScanner

**៧-រឹបអូសបំផ្លាញចោលនូវវត្ថុចាប់យករួមមាន៖** ស្រោមសំបុត្រពណ៌គគីរបិទជិតមានបិទស្លាកបញ្ជាក់ចំនួន ០៥(ប្រាំ)កញ្ចប់ មានផ្ទុកសារធាតុញៀនសម្រាប់ប្រតិកោសលវិច័យ និងនៅសល់ជាក់ស្តែងក្រោយពីការដកសំណាក តាមមាត្រា ៩៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

**៨-រឹបអូសទុកជាទ្រព្យសម្បត្តិរដ្ឋនូវវត្ថុចាប់យករួមមាន៖ ទូរស័ព្ទដៃចំនួន០៨(ប្រាំបី)គ្រឿង** គឺ ម៉ាក VIVO ពណ៌ខ្មៅចំនួន០២គ្រឿង ម៉ាក OPPO ពណ៌ខ្មៅលាយក្រហមចំនួន០១គ្រឿង ម៉ាក Realme ពណ៌ខ្មៅលាយទឹកសមុទ្រចំនួន០១គ្រឿង ម៉ាក Mi ពណ៌ខ្មៅលាយទឹកប្រាក់ចំនួន០១គ្រឿង ម៉ាក NOKIA ពណ៌ខ្មៅលាយទឹកប៊ិចចំនួន០១គ្រឿង ម៉ាក SAMSUNG ពណ៌ខ្មៅលាយទឹកប្រាក់ចំនួន០១គ្រឿង និងម៉ាក OPPO ពណ៌ខ្មៅចំនួន០១គ្រឿង និងម៉ូតូចំនួន០២(ពីរ)គ្រឿង គឺ ម៉ាក HONDA C125 ពណ៌ខ្មៅ លេខម៉ាស៊ីន ND125ME-9116970 ពាក់ស្លាកលេខ ស្វាយរៀង 1D-7537 ចំនួន០១គ្រឿង និងម៉ាក SUZUKI VIVA ពណ៌ខ្មៅ លេខម៉ាស៊ីន BE4CC-TH349239 ពាក់ស្លាកលេខ ភ្នំពេញ 1AE-2610 ចំនួន០១គ្រឿង តាមមាត្រា ៩៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

សាលក្រមនេះ ជំនុំជម្រះជាសាធារណៈនៅថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២២ និងប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទឈ្មោះ [redacted] លីស៊ីថន ឈ្មោះ [redacted] ចន្ថា ឈ្មោះ [redacted] សីហា ឈ្មោះ [redacted] តនា ឈ្មោះ [redacted] ដារ៉ា ឈ្មោះ [redacted] ឡុង ឈ្មោះ [redacted] ចាន់ឌីណា ឈ្មោះ [redacted] សុចិន្តា និងឈ្មោះ [redacted] ម៉ាឡែន និងចាត់ទុកចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ធារិទ្ធ នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២២ ។

បើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

[redacted]

---

| បានឃើញ | បានចម្លងត្រឹមត្រូវតាមច្បាប់ដើម |
|---|---|
| ថ្ងៃពុធ ១៥រោច ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ | ថ្ងៃពុធ ១៥រោច ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ |
| ស្វាយរៀង, ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២២ | ស្វាយរៀង, ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២២ |
| **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** | **ក្រឡាបញ្ជី** |
| [redacted] | [redacted] |



Scanned with CamScanner